# សង្កេតការណ៍ ២៦

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



យុវជនពីរនាក់កំពុងធ្វើការនៅក្នុងរោងចក្រក្រឡឹងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា◆ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌◆www.dccam.org

ខែធ្នូ ឆ្នាំ២០១៣

# មាតិកា

ខែធ្នូ ឆ្នាំ២០១៣

## សវនាការស្តាប់សក្ខីកម្ម


២ កិច្ចប្រជុំរៀបចំសវនាការសម្រាប់សំណុំរឿង០០២/០២

១៣ ការអនុវត្តវិធាននៃភ័ស្តុតាងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

២៤ វិធានការការពារ ជនរងគ្រោះ និងសាក្សី នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

៣០ សិទ្ធិទទួលបានមេធាវីការពារក្តី និងភាពចាំបាច់ក្នុងការអនុវត្តន៍សិទ្ធិនេះនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា



លឹម ជ័យទ័ត្ត, ឌី សុជាតា,
ចាន ប្រាថ្នា, និង ទួន ឡែឃុល

ពិនិត្យ និងផ្ទៀងផ្ទាត់ ដោយ ជី ទេវិទ្ធិ




ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចែកឯកសារជូនសិស្សនិស្សិតនៅសកលវិទ្យាល័យបាត់ដំបង មុនការធ្វើបទបង្ហាញអំពីដំណើរការវិវត្តការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# កិច្ចប្រជុំរៀបចំសវនាការសម្រាប់ ០០២/០២ របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី១១ ដល់ ១២ ខែធ្នូ ឆ្នាំ២០១៣

**ឌី សុជាតា និង ចាន ប្រាថ្នា**

នៅថ្ងៃទី១១-១២ ខែធ្នូ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកកិច្ចប្រជុំរៀបចំសវនាការក្នុងគោលបំណងជួយសម្រួលដល់ការរៀបចំផែនការទុកជាមុនសម្រាប់ធ្វើសវនាការបន្តលើសំណុំរឿង០០២/០២ និងដើម្បីដោះស្រាយទៅលើបញ្ហាបច្ចេកទេស និងការអនុវត្តនានាដែលជាបញ្ហាស្នូលនៃការរៀបចំសំណុំរឿងនេះ ។ កិច្ចប្រជុំនេះធ្វើជាសាធារណៈ ដោយមានការចូលរួមពីសំណាក់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ។ បន្ថែមលើនេះ ដើម្បីសម្រួលដល់កិច្ចពិភាក្សាលើបញ្ហារដ្ឋបាលនៃការរៀបចំសំណុំរឿង០០២នេះ អង្គជំនុំជម្រះសាលាដំបូងបានអញ្ជើញប្រធានស្តី និងអនុប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមកចូលរួមនៅក្នុងកិច្ចប្រជុំនេះ ។ មន្ត្រីរដ្ឋបាលទាំងពីររូបត្រូវឆ្លើយតបនូវសំណួរមួយចំនួនពីសំណាក់អង្គជំនុំជម្រះ និងភាគីនានានៃរឿងក្តី ។ ប្រធានអង្គភាពគាំពារការការពារក្តី ក៏ត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចប្រជុំ ដើម្បីពិភាក្សាអំពីបញ្ហាដែលពាក់ព័ន្ធនឹងថវិកាផ្នែកការការពារក្តីក្នុងករណីចាំបាច់ ។

កិច្ចប្រជុំដែលមានរយៈពេលពីរថ្ងៃនេះ អង្គជំនុំជម្រះ និងភាគីទាំងអស់ បានពិភាក្សាអំពីលទ្ធភាពក្នុងការបង្កើតអង្គជំនុំជម្រះទី២ បញ្ហាបច្ចេកទេស រដ្ឋបាល និងបញ្ហាថវិកាដែលអាចកើតមានឡើង ក្នុងករណីមានការបង្កើតអង្គជំនុំជម្រះទី២នេះ ។ បន្ថែមលើនេះ អង្គជំនុំជម្រះសាលាដំបូងផ្តល់ឱកាសជូនភាគីទាំងអស់ធ្វើការផ្តល់មតិយោបល់ទាក់ទងនឹងការកំណត់វិសាលភាពនៃសំណុំរឿង០០២/០២ ដែលត្រូវជំនុំជម្រះនៅក្នុងដំណាក់កាលទី២ និងកាលបរិច្ឆេទដែលអាចចាប់ផ្តើមធ្វើសវនាការលើអង្គសេចក្តីសម្រាប់សំណុំរឿង០០២/០២ ។

គួររំពុកថា នៅក្នុងព្រឹត្តិបត្រសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមសម្រាប់លេខ២៦នេះ ត្រូវបានបែងចែកជាពីរផ្នែកធំៗ ។ ផ្នែកទី(១) និយាយអំពីកិច្ចប្រជុំរៀបចំសវនាការសម្រាប់សំណុំរឿង០០២/០២ ដែលក្នុងនោះផ្តោតសំខាន់ទៅលើ៖ ១) កិច្ចពិភាក្សាស្តីអំពីការបង្កើតអង្គជំនុំជម្រះទី២, ២) វិសាលភាពនៃសំណុំរឿង០០២/០២ និង ៣) ការពិភាក្សាអំពីកាលបរិច្ឆេទចាប់ផ្តើមសវនាការលើសំណុំរឿង០០២/០២ ។ ចំណែកផ្នែកទី២ ជាប្រភេទអត្ថបទសិក្សាស្រាវជ្រាវដែលនិយាយអំពី៖ ១) ការអនុវត្តវិធាននៃភ័ស្តុតាងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ២) វិធានការការពារ ជនរងគ្រោះ និង សាក្សីនៅអង្គជំនុំជម្រះវិសាមញ្ញ និង ៣) សិទ្ធិទទួលបានមេធាវីការពារក្តីនៅអង្គ ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។



និស្សិតសកលវិទ្យាល័យបាត់ដំបងចូលរួមស្តាប់ការធ្វើបទបង្ហាញរបស់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាអំពីដំណើរការវិវត្តរបស់ការកាត់ទោសមេដឹកនាំខ្មែរក្រហម ។
(បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ផ្នែកទី១ ៖
# កិច្ចប្រជុំរៀបចំសវនាការសម្រាប់សំណុំរឿង ០០២/០២

## ១) ការពិភាក្សាអំពីការបង្កើតអង្គជំនុំជម្រះទី២

នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្ដីដោយមានសំអាងហេតុទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង០០២ ។ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលបានស្នើឲ្យបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ ដែលជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយនានា ក្នុងការធានានូវការចាប់ផ្ដើមការជំនុំជម្រះផ្នែកបន្ទាប់នៃសំណុំរឿង០០២ ឲ្យបានឆាប់រហ័សបំផុត ។ អង្គជំនុំជម្រះតុលាការកំពូលបានចង្អុលបង្ហាញឲ្យអង្គជំនុំជម្រះសាលាដំបូងពិនិត្យមើលលទ្ធភាពដែលមានស្រាប់ ដើម្បីបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ សម្រាប់ជម្រះសំណុំរឿង០០២/០២ ។ ក្នុងគោលបំណងអនុវត្តតាមការបង្គាប់នេះ អង្គជំនុំជម្រះសាលាដំបូងដាក់បញ្ចូលការពិភាក្សាអំពីភាពពាក់ព័ន្ធនឹងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ ទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការនេះ ។

មុននឹងចាប់ផ្ដើមពិភាក្សាអំពីបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ការកត់សម្គាល់ថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងអាចរក្សាបាននូវបុគ្គលិកទាំងអស់របស់ខ្លួន នោះសាលក្រមនៅក្នុងសំណុំរឿង០០២/០១ អាចនឹងប្រកាសនៅក្នុងត្រីមាសទី២ ក្នុងឆ្នាំ២០១៤ ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនឹងចាប់ផ្ដើមសវនាការលើសំណុំរឿង០០២/០២ ភ្លាមបន្ទាប់ពីនោះ ប្រសិនបើវិសាលភាពសម្រាប់ការជំនុំជម្រះនៅក្នុងដំណាក់កាលទី២ នេះអាចកំណត់បានជាមុន ។ អង្គជំនុំជម្រះបានបញ្ជាក់ថា ចៅក្រមទាំងអស់ដែលមាននៅក្នុងក្រុមប្រឹក្សាជំនុំជម្រះបច្ចុប្បន្នរបស់អង្គជំនុំជម្រះសាលាដំបូង ព្រមទាំងបុគ្គលិកគាំទ្របច្ចុប្បន្នទាំងអស់ ចាំបាច់ត្រូវតែផ្ដោតជាចម្បងទៅលើការរៀបចំសាល



យុវជន យុវនារីក្នុងអំឡុងពេលនៃការគស្វ៊ូប្រដាប់អាវុធរបស់ចលនាខ្មែរក្រហមពីចុងទសវត្សរ៍៦០ ឬដើមទសវត្សរ៍៧០ ។
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមក្នុងសំណុំរឿង០០២/០១ ដើម្បីធានាការចេញសាលក្រមបានឆាប់ទាន់ពេលវេលា ។ ហេតុដូច្នេះ បើក្រុមប្រឹក្សាជំនុំជម្រះទី២ ត្រូវបង្កើតឡើងនោះចាំបាច់ត្រូវតែមានចៅក្រមថ្មី ។ អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃបន្ថែមថា ក្រុមប្រឹក្សាជំនុំជម្រះទី២ នឹងត្រូវការមន្ត្រីច្បាប់ជាតិចំនួនប្រាំរូប និងមន្ត្រីច្បាប់អន្តរជាតិចំនួនប្រាំរូប ដើម្បីជួយគាំទ្រដល់កាងាររបស់ក្រុមប្រឹក្សាជំនុំជម្រះទី២នេះ ។

អង្គជំនុំជម្រះបានផ្តល់ឱកាសដើម្បីឲ្យលោកប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលរបស់តុលាការឆ្លើយតបនូវសំណួរមួយចំនួនពាក់ព័ន្ធនឹងលទ្ធភាពក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ ។ ប្រធានអង្គជំនុំជម្រះសាលាដំបូងចៅក្រម និលណុន បានលើកជាសំណួរដើម្បីឲ្យមន្ត្រីផ្នែកការិយាល័យ រដ្ឋបាលធ្វើការបកស្រាយស្តីពីការលើកឡើងរបស់អង្គជំនុំជម្រះតុលាការកំពូលថា «ពុំមានឧបសគ្គផ្នែកហិរញ្ញវត្ថុ ឬផ្នែករដ្ឋបាលទេ ក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២» ។ លោក ក្រាញ់ តូនី ប្រធានរដ្ឋបាលស្តីទីបានឆ្លើយតបថា «ទស្សនទានតម្រូវឲ្យមានអង្គជំនុំជម្រះទី២នេះ ត្រូវធ្វើឡើងតាមសេចក្តីសម្រេចរបស់តុលាការកំពូល ហើយតុលាការកំពូលបានដាក់បញ្ហាឲ្យរដ្ឋបាលពិនិត្យមើលលទ្ធភាពក្នុងការគាំទ្រ ។ ហេតុដូច្នេះ ដូចយើងខ្ញុំបានជម្រាបជូននៅក្នុងអនុស្សរណៈ សូមឲ្យលោកប្រធានសម្រេចទៅលើការបង្កើត ឬមិនបង្កើតសភាទី២នេះ ។ ខាងផ្នែករដ្ឋបាលត្រៀមជានិច្ចក្នុងការគាំទ្រនូវផែនការសកម្មភាពដោយថាហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែករដ្ឋបាល» ។ លោក ឃ្នុត រ៉ូសាន់ហោក បានបន្ថែមថា នៅក្នុងអនុស្សរណៈរបស់ខ្លួន គឺមានជម្រើសពីរ ។ ទី១) អង្គជំនុំជម្រះបច្ចុប្បន្នបន្តដំណើរការទៅមុខទៀត ហើយការិយាល័យរដ្ឋបាលជាអ្នកគាំទ្រដំណើរការនេះ ។ ទី២ ប្រសិនបើអង្គជំនុំជម្រះបច្ចុប្បន្ននេះមិនអាចដំណើរការទៅមុខ បើសិនជាមានជម្រើសផ្សេងទៀត នោះការិយាល័យរដ្ឋបាលនៅតែគាំទ្រដដែល ។ ចៅក្រមអន្តរជាតិ ស៊ីលវៀ ខាតវ្រ៉ាយត៍ បានលើកជាសំណួរទៀតថា «ពាក់ព័ន្ធនឹងលក្ខណៈ និងវិសាលភាពពិតប្រាកដនៃការពិនិត្យឡើងវិញ តើលោកបានធ្វើដែរឬទេ? តើមានស្ថាប័ន ឬបុគ្គលណាខ្លះដែលត្រូវបានពិគ្រោះយោបល់នៅកម្រិតថ្នាក់ជាតិ ឬអន្តរជាតិ? តើមានឧបសគ្គផ្នែកបច្ចេកទេស ឬរដ្ឋបាលដែរឬទេ ប្រសិនបើបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២នោះ?» លោក ក្រាញ់ តូនី បានបញ្ជាក់ថា «ជាគោលការណ៍នៅពេលណា ដែលអង្គជំនុំជម្រះសាលាដំបូង សម្រេចដើរទៅផ្លូវឆ្វេង ឬស្តាំ ត្រូវធ្វើតាមដំណើរការបច្ចុប្បន្ន ឬក៏មានបង្កើតសភាជំនុំជម្រះទី២, ទី៣ និងទី៤នោះ យើងត្រូវពិគ្រោះយោបល់លម្អិតជាមួយផ្នែកពាក់ព័ន្ធទាំងអស់ ។ បើសិនអង្គជំនុំជម្រះសាលាដំបូងជ្រើសរើសបង្កើតសភាជំនុំជម្រះទី២ ខាងផ្នែករដ្ឋបាល ខាងហិរញ្ញវត្ថុក៏ពុំមានឧបសគ្គអ្វីទេ ។ តាមការពិត តុលាការមានរចនាសម្ព័ន្ធគ្រប់គ្រាន់ មានផ្នែកបច្ចេកទេសទូទៅដំណើរការដោយរលូន យ៉ាងហោចយើងត្រូវការអ្នកជំនាញច្បាប់ ឬចៅក្រមមួយចំនួនថែមក្នុងរយៈពេលមួយ» ។ ដូច្នេះ លោកយល់ថា ពុំមានបញ្ហាជាដុំកំភួននោះទេ ។ ចៅក្រម ហ្សង់ម៉ាក ឡាវែញ បានសួរបញ្ជាក់ថាតើការពិភាក្សាយោបល់ឡើងវិញ នៅក្នុងផ្នែករដ្ឋបាលទាក់ទងនឹងការរៀបចំផ្នែកហិរញ្ញវត្ថុនេះដែរឬទេ? លោក តូនី បានបំភ្លឺថា លោកមានកាតព្វកិច្ចធ្វើយ៉ាងណាឲ្យការងាររដ្ឋបាល និងហិរញ្ញវត្ថុរបស់តុលាការនេះអាចដំណើរការទូទៅប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះ ចំណែកសេចក្តីសម្រេចឲ្យមានសភាជំនុំជម្រះទី២ ឬយ៉ាងណាគឺជាយុត្តាធិការរបស់តុលាការ ។ ទាក់ទងនឹងសំណួរស្តីពីការតម្រូវឲ្យមានការពិសោធនកម្មទៅលើកិច្ចព្រមព្រៀងនៅពេលបង្កើតអង្គជំនុំជម្រះទី២ លោក រ៉ូសាន់ហោក បានធ្វើការឆ្លើយតប ។ លោកបានបញ្ជាក់បំភ្លឺចំពោះអនុស្សរណៈ ដែលផ្នែករដ្ឋបាលធ្វើការឆ្លើយឆ្លងទៅអង្គជំនុំជម្រះតុលាការកំពូល ដែលនៅក្នុងនោះការិយាល័យរដ្ឋបាល បានដាក់នូវជម្រើសចំនួនពីរ ។ អនុស្សរណៈដែលការិយាល័យរដ្ឋបាលបានឆ្លើយតបទៅអង្គជំនុំជម្រះតុលាការកំពូល ស្នើសុំឲ្យមានការបំភ្លឺលើការបង្គាប់ឲ្យជ្រើសរើសនូវជម្រើសណាមួយ ដែលអាចធ្វើទៅបាន ។ ការិយាល័យរដ្ឋបាលសុំឲ្យតុលាការកំពូលបញ្ជាក់ថា តើមានភាពចាំបាច់ត្រូវធ្វើការវិសោធនកម្មកិច្ចព្រមព្រៀងដែរឬទេ? មកដល់ពេលនេះ តុលាការកំពូលនៅពុំទាន់ផ្តល់យោបល់មកការិយាល័យរដ្ឋបាលនៅឡើយទេ ។ លោកបន្តទៀតថា ចំពោះសេចក្តីសម្រេចលើដីកាបំបែកកិច្ចដំណើរការនីតិវិធីរបស់តុលាការកំពូលបញ្ជាក់ថា មិន

តម្រូវឲ្យធ្វើវិសោធនកម្មនោះទេ ដូច្នេះអាចអង្គជំនុំជម្រះសាលាដំបូងធ្វើការតាមសិទ្ធិអំណាចរបស់ខ្លួន។ លោក វ៉ូសាន់ហោក បានផ្តល់យោបល់ថា ដោយផ្អែកលើគោលការណ៍នៃអនុស្សរណៈនេះ បើសិនជាមានការស្នើសុំឲ្យការិយាល័យរដ្ឋបាលពិនិត្យ ដូច្នេះ ការិយាល័យរដ្ឋបាលត្រូវតែសួរទៅកាន់ភាគីនៃកិច្ចព្រមព្រៀង។ លោកបន្តទៀតថា ការិយាល័យរដ្ឋបាលពុំបានលើកឡើងពីបញ្ហាច្បាប់ក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ទេ។ អ្វីដែលការិយាល័យរដ្ឋបាលលើកឡើងនោះគឺថា ពុំមានឧបសគ្គពីការិយាល័យរដ្ឋបាលក្នុងការបន្តគាំទ្រអង្គជំនុំជម្រះបច្ចុប្បន្ន ឬអង្គជំនុំជម្រះទី២នោះទេ។ អង្គជំនុំជម្រះបានបន្តសំណួរទាក់ទងនឹងសមាសភាពចៅក្រមបម្រុងបរទេស និងខ្មែរ ដែលត្រូវទទួលការតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីជំនុំជម្រះនៅក្នុងអង្គជំនុំជម្រះសាលាដំបូង។ មន្ត្រីការិយាល័យរដ្ឋបាល បានជម្រាបជូនអង្គជំនុំជម្រះថា នៅក្នុងរចនាសម្ព័ន្ធបច្ចុប្បន្នរបស់តុលាការនេះ មានចៅក្រមបម្រុងខាងភាគីកម្ពុជាចំនួន៥រូប និងភាគីអន្តរជាតិចំនួន៤រូប។ បើសិនជាលោកប្រធានអង្គជំនុំជម្រះយល់ថា ត្រូវការចៅក្រមបម្រុងថ្មីបន្ថែមទៀត លោកប្រធានអាចចាត់តាំងតាមបែបបទជាធរមាន ហើយផ្នែករដ្ឋបាលនឹងចាត់ចែងតាមវិធានការ។ ចំពោះការចំណាយពេលវេលាក្នុងការទំនាក់ទំនងជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ជាទូទៅប្រើរយៈពេលប្រហែលមួយខែ។ ឆ្លើយតបនឹងចម្ងល់របស់ចៅក្រម ហ្សង់ម៉ាកឡាវែញ លើសមាសភាពចៅក្រមបម្រុងចំនួន៥រូប លោកប្រធានស្តីទីនៃការិយាល័យរដ្ឋបាលបានបញ្ជាក់ថា ចៅក្រមបម្រុងទាំង៥រូប មានដូចជា អង្គជំនុំជម្រះសាលាដំបូងមួយរូប អង្គបុរេជំនុំជម្រះមួយរូប អង្គជំនុំជម្រះតុលាការកំពូលមួយរូប ការិយាល័យសហចៅក្រមស៊ើបអង្កេតមួយរូប និងការិយាល័យសហព្រះរាជអាជ្ញាមួយរូប។ លោកស្រីចៅក្រម ស៊ីលវៀ ខាតព្រ៉ាយត៍ បានបន្តសំណួរទាក់ទងនឹងសមត្ថកិច្ចរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូង ក្នុងការតែងតាំងចៅក្រមបម្រុងទាំងនោះ។ លោក ក្រាញ់ តូនី បានឆ្លើយតបថា អង្គជំនុំជម្រះមានសមត្ថកិច្ចផ្តាច់មុខលើការចាត់ចែងផ្នែកច្បាប់ ប៉ុន្តែ ចំពោះលទ្ធភាពថាតើអង្គជំនុំជម្រះសាលាដំបូងអាចចាត់តាំងចៅក្រមបម្រុងបានឬមិនបាន គឺពុំមែនជាការវាយតម្លៃរបស់លោកនោះទេ។ ចំណែកលោក ឃ្លុត វ៉ូសាន់ហោក បានបន្ថែមថា បើសិនជាអង្គជំនុំជម្រះសាលាដំបូងគិតថាពុំមានសមត្ថកិច្ចចាត់ចែងលើករណីនេះទេ ក្រុមការងាររបស់លោកនឹងស្វែងរកការបកស្រាយពីខាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ លោកប្រធានអង្គជំនុំជម្រះ បានលើកឡើងជាសំណួរទាក់ទងនឹងគុណភាពរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការចាត់តាំងចៅក្រមពីអង្គភាពផ្សេងៗ មកធ្វើការនៅក្នុងអង្គជំនុំជម្រះសាលាដំបូងក្នុងន័យបង្កើតឲ្យបានក្រុមប្រឹក្សាជំនុំជម្រះទី២។ ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងពុំទទួលការអនុញ្ញាតដោយច្បាប់ណាមួយ ដែលផ្តល់អំណាចឲ្យអង្គជំនុំជម្រះសាលាដំបូងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចាត់តាំងចៅក្រមទាំងឡាយនៅក្នុងតុលាការនេះ ដើម្បីបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ទេ។ សូម្បីនៅក្នុងអង្គជំនុំជម្រះសាលាដំបូងផ្ទាល់ នៅពេលដែលត្រូវការកែសម្រួលភារកិច្ចពីចៅក្រមបម្រុងមួយរូបទៅជាចៅក្រមពេញសិទ្ធិ និងពីចៅក្រមពេញសិទ្ធិមកជា ចៅក្រមបម្រុង ក៏ត្រូវរៀបចំដោយព្រះរាជក្រឹត្យដែរ។

សហព្រះរាជអាជ្ញាអន្តរជាតិ នីកូឡាស គុំចាន់ បានលើកជាសំណួរទៅកាន់មន្ត្រីការិយាល័យរដ្ឋបាលលទ្ធភាពផ្គត់ផ្គង់ថវិកាសម្រាប់មន្ត្រីច្បាប់ដែលសហព្រះរាជអាជ្ញាត្រូវការចំនួន១០រូប រួមមានភាគីជាតិ៥រូប និងអន្តរជាតិ៥រូប សម្រាប់ការជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២។ ចម្លើយដ៏ខ្លីពីលោកប្រធានការិយាល័យរដ្ឋបាល គឺអាចមានលទ្ធភាពធ្វើទៅបាន។ លទ្ធភាពក៏អាចទៅរួចដែរ បើទោះបីជាសហព្រះរាជអាជ្ញាស្នើសុំឲ្យមានការចាប់ផ្តើមសំណុំរឿង០០២/០២ ដំណាលគ្នាជាមួយនឹងពេលចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០១។ សហព្រះរាជអាជ្ញាជាតិ លោកស្រី ជា លាង បានលើកយកបញ្ហាថវិកាសម្រាប់ទ្រទ្រង់ដល់បុគ្គលិកថ្មី និងធនធានមនុស្សដែលនឹងត្រូវជ្រើសរើសយកមកបម្រើការងារនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញា មានការព្រួយបារម្ភចំពោះការលំបាករបស់បុគ្គលិកថ្មីដែលត្រូវមកបំពេញការងារនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា។ បុគ្គលិកថ្មី ត្រូវចំណាយពេលច្រើនក្នុងសិក្សាលើរឿងក្តី។ លោកអនុប្រធានការិយាល័យរដ្ឋបាលបានបំភ្លឺថា

ថវិការមិនមែនជាបញ្ហាចោទនោះទេ ដោយសារអាចមានលទ្ធភាពបត់បែន ដើម្បីគ្រប់គ្រងលើការចំណាយក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចបង្កើតសភាទី២ ។ ចំពោះការជ្រើសរើសបុគ្គលិកផ្នែកទៅតាមបែបបទដែលអនុវត្តកន្លងមក ដូចជាការផ្សព្វផ្សាយ ការជ្រើសរើស និងការធ្វើបទសម្ភាសន៍ ជាដើម ប៉ុន្តែមិនចំណាយពេលយូរពេកនោះទេ ។ សហព្រះរាជអាជ្ញាជាតិបានជូនជាយោបល់ថា ក្នុងនាមជាសមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមផ្ទាល់ និងដូចអ្វីដែលប្រធានអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងរួចមកហើយ ការតែងតាំងអង្គជំនុំជម្រះឬការប្តូរសមាសភាពពីចៅក្រមបម្រុងមកជាចៅក្រមពេញសិទ្ធិត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ដែលចេញដោយព្រះមហាក្សត្រដែលជាប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ចៅក្រមស៊ីលវៀ ខាតព្រ៉ាយត៍ បានសួរយោបល់របស់ភាគី សហព្រះរាជអាជ្ញា ក្នុងករណីដែលអង្គជំនុំជម្រះតែងតាំងចៅក្រមពេញសិទ្ធិសម្រាប់សភាជំនុំជម្រះទី២ ដែលជ្រើសពីចៅក្រមបម្រុងម្នាក់នៅការិយាល័យសហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាជាតិ ជា លាង បានជម្រាបថា ចៅក្រមបម្រុងមកពីការិយាល័យសហព្រះរាជអាជ្ញា លោក ដួន ស៊ុនឡេង សព្វថ្ងៃពុំមានសមត្ថភាពបំពេញការងារបានឡើយ ដោយសារកំពុងមានជំងឺលើសឈាមបណ្តាលឲ្យស្លាប់មួយចំហៀងខ្លួន ។ សហព្រះរាជអាជ្ញាអន្តរជាតិ នីកូឡាស បានបន្ថែមថា ខាងសហព្រះរាជអាជ្ញា អន្តរជាតិពុំមានបម្រុងទេ ។ ដូច្នេះ ពុំមានលទ្ធភាពក្នុងការតែងតាំងចៅក្រមបម្រុងខាងភាគីជាតិ និងអន្តរជាតិនោះទេ ។ ម្យ៉ាងទៀត ប្រសិនបើព្រះរាជអាជ្ញាចូលរួមនៅក្នុងសមាជិកក្រុមប្រឹក្សាជំនុំជម្រះទី២ នាំឲ្យមានទំនាស់ផលប្រយោជន៍ ។ លោកបន្តទៀតថា នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ពុំមានខុសគ្គក្នុងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២ទេ ហើយអាចជួយសម្រួលដល់ផលប្រយោជន៍យុត្តិធម៌ ។ បើសិនលោកប្រធានយល់ឃើញថា ចៅក្រមបម្រុងមកពីផ្នែកផ្សេងៗត្រូវទទួលការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនោះ គួរតែដាក់សំណើនេះទៅខាងការិយាល័យរដ្ឋបាលឲ្យសម្របសម្រួលសំណើនេះ ។

លោកប្រធានអង្គជំនុំជម្រះសាលាដំបូង បានសង្កត់ធ្ងន់លើបញ្ហាទំនាស់ផលប្រយោជន៍ក្នុងករណីជ្រើសរើសក្រុមប្រឹក្សាជំនុំ


កម្មាភិបាលខ្មែរក្រហមកំពុងកកាយហិបដែលផ្ទុកទៅដោយក្រដាស់ប្រាក់កាលពីសម័យ លន់ នល់ ដែលលែងមានតម្លៃនៅ ក្នុងរបបខ្មែរក្រហម ។ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជម្រះទី២ពីផ្នែកផ្សេងៗ ។ ច្បាប់ជាតិកម្ពុជា បានចែងច្បាស់អំពីវិសមត្ថភាពរវាងតួនាទីរបស់ព្រះរាជអាជ្ញាក្នុងការចាត់ការសំណុំរឿង មិនអាចយកមកជំនុំជម្រះរឿងក្តីដដែលបានទេ ។ម្យ៉ាងទៀត នៅក្នុងរឿងក្តីតែមួយពុំអាចយកសមាសភាពសភាស៊ើបសួរមកធ្វើជាចៅក្រមជំនុំជម្រះលើរឿងក្តី ដែលខ្លួនធ្លាប់បានចូលការងារនៅក្នុងតុលាការកំពូលបានពិនិត្យ និងពិភាក្សាលើសេចក្តីសម្រេចនានា ដែលប្រឆាំងនឹងកិច្ចដំណើរការរបស់អង្គជំនុំជម្រះសាលាដំបូងដែលសម្រេចកន្លងមករួចមក ។

មេធាវី វ៉ិចទ័រ កូប៉េ ការពារក្តី នួន ជា បានលើកសំណួរទាក់ទងនឹងបញ្ហាថវិការសម្រាប់ផ្គត់ផ្គង់ក្រុមមេធាវីការពារក្តី ។



រូបថតអនុស្សាវរីយ៍របស់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹងនិស្សិតសកលវិទ្យាល័យស្វាយរៀង បន្ទាប់

រួមស៊ើបអង្កេតនោះទេ ។ លើសពីនេះ ជាទូទៅការអនុវត្តតែងតែបញ្ជូនចៅក្រមពីក្រោមទៅលើតាមលំដាប់លំដោយពុំធ្វើការបញ្ជូនពីលើចុះក្រោម ដូចជាការបញ្ជូនចៅក្រមបម្រុងនៅអង្គជំនុំជម្រះតុលាការកំពូលមកធ្វើជាចៅក្រមពេញសិទ្ធិនៅអង្គជំនុំជម្រះសាលាដំបូងទេ ។ ឧទាហរណ៍ ចៅក្រមបម្រុងដែលបានបំពេញលោក ឃុត វ៉ូសាន់ហោក បានឆ្លើយតបថា ដោយសារផែនការសង្គ្រោះបន្ទាន់ ឬថវិកាសង្គ្រោះបន្ទាន់របស់ខាងមេធាវីការពារទាំងផ្នែកជាតិ និងអន្តរជាតិ ស្ថិតក្រោមការទូរទាត់ពីថវិកាអន្តរជាតិ ដូច្នេះពុំមានភាពខុសគ្នារវាងបុគ្គលិកជាតិ និងអន្តរជាតិនោះឡើយ ។ ចំពោះការស្នើសុំថវិកាបន្ថែមនៅក្នុងការរយៈពេលដែល

ត្រូវត្រៀមបណ្តឹងសាទុក្ខនៃសំណុំរឿង០០២/០១ ខាងផ្នែករដ្ឋបាលនឹងអនុវត្តការងារដូចគ្នាចំពោះភាគីមេធាវីការពារក្តី និងសហព្រះរាជអាជ្ញា បើមានសំណើសុំពីភាគីទាំងពីរ ។ មេធាវីបានលើកឡើងទៀតថា ចំពោះការយល់ឃើញរបស់ខ្លួនពុំមានខបសគ្គផ្លូវច្បាប់ ក្នុងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២នោះទេ ។ ច្បាប់ក្នុងការតែងតាំងចៅក្រមបម្រុងទៅជាចៅក្រមពេញសិទ្ធិនោះទេ ។

ក្រុមមេធាវីការពារក្តី ខៀវ សំផន បានលើកឡើងទាក់ទងនឹងសំណួរស្តីពីការតែងតាំងរបស់ក្រុមប្រឹក្សាជំនុំជម្រះទី២ថា តើត្រូវសម្រេចដោយអង្គការសហប្រជាជាតិ ឬអង្គជំនុំជម្រះតុលា



ពីការធ្វើបទបង្ហាញអំពីដំណើរការវិវត្តការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

បញ្ហាដែលអាចកើតឡើងនោះគឺការតែងតាំងមានភាពលម្អៀង ។ មេធាវីបានបញ្ជាក់ដែរថា ចៅក្រមបម្រុងនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ចៅក្រម ហ្វេនស៍ ក៏អាចក្លាយជាសមាជិកមួយរូបនៃក្រុមប្រឹក្សាជំនុំជម្រះទី២ដែរ ដោយសារគាត់យល់ដឹងអំពីសំណុំរឿងនេះច្រើន ។ ក្រុមរបស់លោកគិតថា ពុំមានខបសគ្គផ្លូវ ការកំពូល? លោក ឃ្លុត រ៉ូសាន់ហោក បានជម្រាបថា “តាមទស្សនៈរបស់ការិយាល័យរដ្ឋបាល គឺស្នើសុំឲ្យមានការបំភ្លឺពីអង្គជំនុំជម្រះតុលាការកំពូលថា តើមានចេតនាធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងឬយ៉ាងណា” ។ កិច្ចព្រមព្រៀងបានចែងថា “លោកអគ្គលេខាធិការអង្គការសហប្រជាជាតិនឹងបញ្ជូនបញ្ជីឈ្មោះបេក្ខ

ជន សម្រាប់តំណែងជាចៅក្រមអន្តរជាតិយ៉ាងតិចប្រាំពីររូប ហើយពីក្នុងបញ្ជីនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងតែង តាំងចំនួនប្រាំរូប ដើម្បីបម្រើការងារជាចៅក្រមនៅក្នុងអង្គជំនុំជម្រះក្តីទាំងពីរថ្នាក់ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែងតាំងចៅក្រមអន្តរជាតិដោយយកពីក្នុងបញ្ជីឈ្មោះ ដែលអគ្គលេខាធិការអង្គការសហប្រជាជាតិបានប្រគល់ជូនតែប៉ុណ្ណោះ» ។ មេធាវី គង់ សំអុន បានបង្ហាញពីជំហរ ដែលពុំគាំទ្រឲ្យមានការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ ដើម្បីកាត់ទោសកូនក្តីរបស់ខ្លួននោះទេ ។

ដោយឡែក មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បេនី យេ បានឡើងបង្ហាញពីគោលជំហរជំនួសសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលអវត្តមាននៅក្នុងកិច្ចប្រជុំនាថ្ងៃនោះថា ក្រុមប្រឹក្សាជំនុំជម្រះទី២ ពុំមានភាពចាំបាច់តម្រូវឲ្យមាននោះទេ ។ ដូច្នេះ ក្រុមរបស់ខ្លួនពុំគាំទ្រឲ្យមានការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២នោះទេ ។ ជាបឋម មេធាវីបានបង្ហាថា អំណាចរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូងក្នុងការចាត់តាំងចៅក្រមពេញសិទ្ធិពីសមាសភាពចៅក្រមបម្រុង មានលក្ខណៈសង្ស័យច្រើន បើផ្អែកតាមការបកស្រាយរបស់អង្គជំនុំជម្រះតុលាការកំពូល ។ ទោះបីជាមានការអនុវត្តតាមការបកស្រាយនេះ ហើយមានការសន្មតថា ប្រធានអង្គជំនុំជម្រះសាលាដំបូងមានអំណាចក្នុងការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះទី២ក៏ដោយ តុលាការកំពូលត្រូវតែផ្តល់ឆន្ទានុសិទ្ធិឲ្យប្រធានអង្គជំនុំជម្រះសាលាដំបូងធ្វើការតែងតាំងក្នុងករណីចាំបាច់ទាក់ទងនឹងផលប្រយោជន៍យុត្តិធម៌ ។ ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ផលប្រយោជន៍យុត្តិធម៌មិនតម្រូវឲ្យមានក្រុមប្រឹក្សាជំនុំជម្រះទី២នោះទេ ដោយសារ វាមិនអាចនាំឲ្យការជំនុំជម្រះនេះដំណើរការបានលឿន ។ ឆ្លងកាត់ការពិភាក្សាកន្លងមក ការជ្រើសរើសក្រុមប្រឹក្សាជំនុំជម្រះទី២ ត្រូវចំណាយពេលច្រើន ។ ចៅក្រមជាតិត្រូវជ្រើសរើសពីចៅក្រមបម្រុង ហើយតម្រូវឲ្យមានការតែងតាំងដោយព្រះរាជក្រឹត្យ ។ ចំពោះចៅក្រមអន្តរជាតិ ត្រូវជ្រើសពីបញ្ជីរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ចំណែកបុគ្គលិកគាំទ្រ ត្រូវជ្រើសរើសតាមនីតិវិធីដែលតម្រូវឲ្យមានការប្រកាសជ្រើសរើសបុគ្គលិករហូតដល់ដំណាក់កាលសម្ភាស ។ លើសពីនេះក្រុមប្រឹក្សាជំនុំជម្រះទី២ ធ្វើយ៉ាងណាទាមទារឲ្យយល់នូវឯកសារនានាដែលមាននៅក្នុងសំណុំរឿង០០២/០១ ដែលនឹងត្រូវប្រើពេលយូរ



កម្មាភិបាលខ្មែរក្រហមកំពុងធ្វើការនៅក្នុងរោងចក្រអំបោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ថែមទៀត ។ មេធាវីបានបន្តថា ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះទី២ ត្រូវបង្កើតឡើងពិតមែន បានន័យថា បង្កើតឡើងនៅមុនពេលចេញសាលក្រមនៃសំណុំរឿង០០២/០១ តែបន្តិចប៉ុណ្ណោះ ។ ដូច្នេះ ពុំមានប្រសិទ្ធភាពឲ្យបានឆាប់រហ័សនោះដែរ ។ មេធាវីចង់ឲ្យក្រុមប្រឹក្សាជំនុំជម្រះបច្ចុប្បន្ននេះ ជាអ្នកជំនុំជម្រះវគ្គទី២ ឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ដោយមានការកំណត់វិសាល ភាពនៃបទល្មើស និងបញ្ជីឈ្មោះសាក្សីនៅក្នុងសំណុំរឿង ០០២/០២ ។

ឈានចូលដល់របៀបវារៈបន្ទាប់របស់កិច្ចប្រជុំនេះ អង្គជំនុំជម្រះបានសាកសួរមន្ត្រីទាំងពីររូបមកពីការិយាល័យរដ្ឋបាលអំពីរចនាសម្ព័ន្ធថវិការបស់តុលាការនេះសម្រាប់រយៈពេលពីរឆ្នាំ (២០១៤-២០១៥) ។ បញ្ហាមានពីរៈ ទី១) ដំណើរការថវិកា និងទី២) ស្ថានភាពផ្តល់មូលនិធិ ។ ដំណើរការថវិកា គឺជាដំណើរការរួមរវាងការិយាល័យរដ្ឋបាលជាមួយនឹងផ្នែក ឬអង្គភាពនានារបស់តុលាការ ។ ខាងការិយាល័យរដ្ឋបាលបានដាក់បង្ហាញនូវសំណើថវិកាដែលមានទម្រង់ជាពង្រាងនៅឡើយ ទៅទីក្រុងញូវយ៉កនៅខែវិច្ឆិកា ឆ្នាំ២០១៣ ។ ក្នុងពេលបច្ចុប្បន្ននេះ គម្រោងថវិកានេះត្រូវពិភាក្សាក្នុងចំណោមប្រទេសផ្តល់ជំនួយ និងមានការចោទសួរទៅវិញទៅមករវាងការិយាល័យរដ្ឋបាល ជាមួយប្រទេសផ្តល់ជំនួយ ។ ប្រទេសផ្តល់ជំនួយគាំទ្រដល់តុលាការ និងចូលរួមយ៉ាងសកម្មក្នុងការបែងចែកថវិកាទាំងអស់នោះ ។ ប្រទេសទាំងអស់នោះបានប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លា ប៉ុន្តែពួកគេនៅពុំទាន់បញ្ជាក់ឲ្យបានច្បាស់លាស់អំពីចំនួនឧបត្ថម្ភនៅឡើយ ។

### ២) ការពិភាក្សាអំពីវិសាលភាពនៃសំណុំរឿង ០០២/០២

ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា *"តាមបុរេលក្ខខណ្ឌជាក់ស្តែងមួយចំនួន សហព្រះរាជអាជ្ញាអាចមានលទ្ធភាពដកចេញនូវការចោទប្រកាន់ខ្លះ ដោយស្របតាមផ្លូវច្បាប់"* ។ តាមរយៈសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា មានបញ្ហាផ្លូវច្បាប់ដ៏ស្មុគស្មាញមួយចំនួនដែលត្រូវដោះស្រាយ ។ ភាពស្មុគស្មាញនោះគឺថា តើមានបទដ្ឋានណា ដែលអនុញ្ញាតឲ្យសហព្រះរាជអាជ្ញា ឬអង្គជំនុំជម្រះសាលាដំបូងមានលទ្ធភាពដកចេញ ឬទម្លាក់ចោលនូវផ្នែកខ្លះនៃបទចោទប្រកាន់ ឬទីតាំងឧក្រិដ្ឋកម្ម ដោយមិនចាំបាច់ជំនុំជម្រះ ព្រោះច្បាប់កម្ពុជាពុំមានចែង ។ អង្គជំនុំជម្រះទទួលស្គាល់ថា ភាគីទាំងអស់ពុំត្រូវបានផ្តល់ឱកាសឲ្យបានគ្រប់គ្រាន់ដើម្បីពិភាក្សាអំពីបញ្ហាដ៏ស្មុគស្មាញនេះទេ ។ ទោះបីជាយ៉ាងណាក្តីអង្គជំនុំជម្រះសាលាដំបូងទទូចសុំឲ្យភាគីទាំងអស់ លើកឡើងអំពីបញ្ហានេះ និងបង្ហាញជាបឋមនូវជំហររបស់ខ្លួនទាក់ទងនឹងបទចោទ និងទីតាំងឧក្រិដ្ឋកម្ម ដែលត្រូវដាក់បញ្ចូលជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២ ។ អង្គជំនុំជម្រះបានផ្តល់វេទិកាជាបន្តបន្ទាប់ជូនភាគីដោយចាប់ផ្តើមពីសហព្រះរាជអាជ្ញា ក្រុមមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តីជនជាប់ចោទទាំងពីរក្រុម ។

ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង០០២/០២ សហព្រះរាជអាជ្ញាអន្តរជាតិ នីកូឡាស គុំចាន់ ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបញ្ចូលបទចោទប្រកាន់ដែលនៅសេសសល់ទាំងអស់ នៅក្នុងសំណុំរឿងនេះ ។ បទល្មើសទាំងនោះរួមមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ លោក នីកូឡាស បញ្ជាក់ទៀតថា បទចោទទាំងនេះពុំចាំបាច់តម្រូវឲ្យបញ្ចូលទីតាំងឧក្រិដ្ឋកម្មទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះនោះទេ ពោលគឺទីតាំងឧក្រិដ្ឋកម្មមួយចំនួននឹងត្រូវបានតំណាង ឬដកចេញ ។ លោក នីកូឡាស អះអាងថា ការអនុវត្តបែបនេះ ធ្វើឲ្យសវនាការកាន់តែមានប្រសិទ្ធភាព និងឆាប់រហ័ស ពីព្រោះការជំនុំជម្រះនឹងត្រូវការពេលវេលាប្រមាណតែ ៩៦ថ្ងៃប៉ុណ្ណោះ ក្នុងការបញ្ចប់សំណុំរឿង០០២/០២ ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឌេល លីសាក់ បានបញ្ជាក់បន្ថែមថា ដំណើរការជំនុំជម្រះលើសំណុំរឿង០០២/០២ នឹងចំណាយពេលវេលាខ្លីជាងសំណុំរឿង០០២/០១ ព្រោះការសួរដេញដោលសាក្សីនឹងប្រើពេលវេលាខ្លី ។ សាក្សីម្នាក់ៗអាចនឹងត្រូវចំណាយពេលសួរដេញដោលតែកន្លះថ្ងៃ ឬមួយភាគបួននៃថ្ងៃប៉ុណ្ណោះ ។ និយាយម្យ៉ាងទៀត អង្គជំនុំជម្រះអាចស្តាប់សក្ខីកម្មសាក្សីចំនួន ២ ទៅ ៤ នាក់ក្នុងមួយថ្ងៃ ។ ឌេល លីសាក់ ធ្វើការគណនា ឬប៉ាន់ស្មានពេលវេលានេះដោយផ្អែកទៅលើបទពិសោធនៅក្នុងសំណុំរឿង០០២/០១ ដែលក្នុង១ថ្ងៃ អង្គជំនុំជម្រះអាច

ស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានចំនួន ៤រូប ។ ខេល លីសាក់ បញ្ជាក់ថា ការសួរដេញដោលសាក្សីនៅក្នុងសំណុំរឿង ០០២/០២ នឹងប្រើពេលខ្លីៗប៉ុណ្ណោះ ហើយមិនមានភាពស្មុគស្មាញដូចការសួរដេញដោលនៅក្នុងសំណុំរឿង០០២/០១ឡើយ ។ សាក្សីទាំងនោះនឹងមិនមានការសួរដេញដោលទាក់ទងនឹងតួនាទីជនជាប់ចោទ ប្រព័ន្ធទំនាក់ទំនងការផ្សាប្រវត្តិនិងដំណើរការរបស់បក្សកុម្មុយនីស្តកម្ពុជា ។ល។ ដូចនៅក្នុងសវនាការជំណាក់កាលទី១ (សំណុំរឿង០០២/០១) ឡើយ ព្រោះអង្គហេតុទាំងនេះសួរដេញដោលរួចហើយ ហើយឯកសារកំណត់ហេតុទាំងនោះនឹងដាក់បញ្ចូលក្នុងសំណុំរឿង០០២/០២ ។ ដូច្នេះ ការសួរដេញដោលសាក្សីនៅក្នុងសវនាការជំណាក់កាលទី២ (សំណុំរឿង០០២/០២) គឺផ្តោតលើតែអង្គហេតុឧក្រិដ្ឋកម្មជាក់លាក់ ដែលនឹងត្រូវប្រើពេលវេលាខ្លីៗប៉ុណ្ណោះ ។ ភ្ជាប់ជាមួយបញ្ហានេះ ខេល លីសាក់ បានផ្តល់ការកត់សម្គាល់ថា ដើម្បីឲ្យការជំនុំជម្រះលើសំណុំរឿង០០២/០២ មានប្រសិទ្ធភាព និងឆាប់រហ័ស សំណុំរឿងនេះត្រូវជំនុំជម្រះដោយអង្គជំនុំជម្រះដដែល ព្រោះអង្គជំនុំជម្រះនេះបានយល់ដឹងអំពីកិច្ចដំណើរការនីតិវិធី និងភស្តុតាងដែលបានសួរដេញដោលរួច ហើយនៅក្នុងសំណុំរឿង០០២/០១ ។ តាមការលើកឡើងរបស់ ខេល លីសាក់ ការបង្កើតអង្គជំនុំជម្រះទី២ គឺពុំមានភាពចាំបាច់ឡើយ ព្រោះការជំនុំជម្រះលើសំណុំរឿង ០០២/០២ ដោយអង្គជំនុំជម្រះថ្មីនេះនឹងធ្វើឲ្យមានភាពយឺតយ៉ាវជាងការជំនុំជម្រះដោយអង្គជំនុំជម្រះដែលមានស្រាប់ ។

ទាក់ទងទៅនឹងបទដ្ឋានដែលអនុញ្ញាតឲ្យដកចេញ ឬទម្លាក់ចោលនូវផ្នែកខ្លះនៃបទចោទ ឬទីតាំងឧក្រិដ្ឋកម្ម ខេល លីសាក់ បញ្ជាក់ថា សហព្រះអាជ្ញាបានយោងទាំងស្រុងទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលអនុញ្ញាតឲ្យធ្វើបែបនេះ ។ សហព្រះរាជអាជ្ញាអន្តរជាតិ នីកូឡាស គុំចាន់ បន្ថែមថា អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិអំណាចក្នុងការជ្រើសរើសយកបទចោទ ឬទីតាំងឧក្រិដ្ឋកម្មក្នុងកម្រិតអប្បបរមាមកធ្វើការជម្រះសេចក្តីបាន ។ សិទ្ធិអំណាចនេះស្របតាមវិធាន និងការអនុវត្តរបស់តុលាការអន្តរជាតិផ្សេងៗទៀតដែលជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។ សិទ្ធិនេះទំនងជាសហព្រះរាជអាជ្ញា នីកូឡាស គុំចាន់ យោងទៅរកវិធានផ្ទៃក្នុងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលចែងថា “បន្ទាប់ពីស្តាប់រដ្ឋអាជ្ញា ដើម្បីជាប្រយោជន៍នៃការជំនុំជម្រះក្តី ប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូងស្នើឲ្យរដ្ឋអាជ្ញាកាត់បន្ថយបទចោទប្រកាន់ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងអាចកំណត់ចំនួនទីតាំងឧក្រិដ្ឋកម្ម ឬហេតុការណ៍នៅក្នុងការចោទ ប្រកាន់មួយ ឬច្រើន” ។ គួរបញ្ជាក់ថា វិធាននេះត្រូវបានលើកឡើងដោយចៅក្រម និល ណុន ក្នុងអំឡុងពេលអង្គជំនុំជម្រះស្តាប់ការលើកឡើងអំពីការកំណត់វិសាលភាពនៃសំណុំរឿង០០២/០២ ។

សហមេធាវីជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ពេជ អង្គ គាំទ្រទាំងស្រុងចំពោះសំណើរបស់សហព្រះរាជអាជ្ញា នីកូឡាស គុំចាន់ ដែលសុំឲ្យអង្គជំនុំជម្រះបញ្ចូលបទល្មើសដែលនៅសេសសល់ទាំងអស់ ទៅក្នុងសំណុំរឿង០០២/០២ ។ ជាងនេះទៅទៀត សាលក្រមសម្រាប់សំណុំរឿង០០២/០២នេះ ត្រូវសម្រេចឲ្យបានក្នុងរយៈពេលមួយសមរម្យ ដើម្បីផលប្រយោជន៍យុត្តិធម៌សម្រាប់ជនជាប់ចោទ និងជនរងគ្រោះដែលមានវ័យចាស់ជរា ។ ប៉ុន្តែ ពេជ អង្គ ពុំបានបង្ហាញជំហរគាំទ្រ ឬជំទាស់ច្បាស់លាស់ចំពោះការផ្តួចផ្តើមរបស់សហព្រះរាជអាជ្ញាដែលសុំឲ្យដកចេញ ឬទម្លាក់ចោលនូវអង្គហេតុ ឬទីតាំងឧក្រិដ្ឋកម្មខ្លះនោះឡើយ ដោយបញ្ជាក់ថា សិទ្ធិនេះគឺអាស្រ័យទៅលើអង្គជំនុំជម្រះ ។ មេធាវី ពេជ អង្គ លើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ចង់ដឹងរឿងរ៉ាវពិតប្រាកដ និងអ្នកដែលទទួលខុសត្រូវចំពោះអង្គហេតុ និងទីតាំងឧក្រិដ្ឋកម្មដែលគាត់ទទួលរងគ្រោះ ។ ដូច្នេះ ក្នុងករណីមានការដកចេញ ឬទម្លាក់ចោលអង្គហេតុ ឬទីតាំងឧក្រិដ្ឋកម្មណាមួយនោះដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងគ្រោះដោយសារអង្គហេតុ ឬទីតាំងឧក្រិដ្ឋកម្មនោះ នឹងបាត់បង់ឱកាសនេះ ហើយរឿងរ៉ាវឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ ក៏ពុំត្រូវបាននិយាយចេញ និងដឹងឮដល់សាធារណជនដែរ ។ មេធាវីអន្តរជាតិ បេនី យេ អះអាងបន្ថែមថា បទចោទគឺមិនអាចទម្លាក់ចោលបានឡើយ ព្រោះបទចោទគឺជាការកំណត់តាមផ្លូវច្បាប់ទៅលើអង្គហេតុដែលបានកើតឡើង ។

ផ្ទុយពីការលើកឡើងរបស់សហព្រះរាជអាជ្ញា មេធាវីអន្តរ

ជាតិ វិចទ័រ កូប៉េ ការពារក្តីជនជាប់ចោទ នួន ជា បានអះអាងថា ការជំនុំជម្រះលើសំណុំរឿង០០២/០២ នឹងត្រូវប្រើពេលវេលាយូរ និងមានភាពស្មុគស្មាញដូចការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ដែរ ។ សំណុំរឿងនេះនឹងត្រូវបញ្ចូលនូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលជាឧក្រិដ្ឋកម្មមួយមានលក្ខណៈស្មុគស្មាញក្នុងការបង្ហាញ និងចោទប្រកាន់ ។ បន្ថែមលើនេះទៀត អង្គហេតុឧក្រិដ្ឋកម្មដែលកើតនៅមន្ទីរសន្តិសុខស-២១ ក៏នឹងត្រូវដាក់បញ្ចូលនៅក្នុងសំណុំរឿង០០២/០២ តាមការចង្អុលបង្ហាញរបស់តុលាការកំពូលដែរ ។ អង្គហេតុនេះក៏មានភាពស្មុគស្មាញក្នុងការបង្ហាញអំពីតួនាទី និងការទទួលខុសត្រូវរបស់ កាំង ហ្គេកអ៊ាវ (ហៅ ឌុច) និង នួន ជា ។ តាមការលើកឡើងរបស់មេធាវី វិចទ័រ កូប៉េ វិសាលភាពនៃសំណុំរឿង០០២/០២ ដែលកំណត់ដោយតុលាការកំពូល ដោយក្នុងនោះមានដាក់បញ្ចូលនូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងមន្ទីរសន្តិសុខស-២១ ។ល។ អាចធ្វើឲ្យក្រុមមេធាវីការពារក្តីបង្កើតទ្រឹស្តី ឬយុទ្ធសាស្ត្រគ្រប់គ្រាន់ក្នុងការការពារកូនក្តីខ្លួន ពោលគឺពុំចាំបាច់បន្ថែមអង្គហេតុផ្សេងៗទៀតឡើយ ។ មេធាវី វិចទ័រ កូប៉េ បានបង្ហាញជំហរច្រានចោលចំពោះការប៉ុនប៉ងដាក់បញ្ចូលអង្គហេតុស្តីពីការជម្លៀសប្រជាជននៅដំណាក់កាលទី៣ នៅក្នុងសំណុំរឿង០០២/០២ និងបញ្ជាក់ថា នៅពេលជំនុំជម្រះភាគីអាចពិភាក្សាគ្នាក្នុងការដាក់ ឬមិនដាក់បញ្ចូលអង្គហេតុមួយ ឬច្រើនតាមការចាំបាច់ ។ ទោះបីជាយ៉ាងណាមេធាវី វិចទ័រ កូប៉េ បានបង្ហាញ អំពីផលលំបាកក្នុងការសួរដេញដោលសាក្សី ដោយសារសំណួររបស់ខ្លួនក្នុងការបង្ហាញការពិត អាចស្ថិតនៅក្នុង ឬក្រៅវិសាលភាពនៃអង្គហេតុដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង០០២/០២ ។

ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង០០២/០២នេះដែរ មេធាវី អង់តា ហ្គីសេ ជាសហមេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ ខៀវ សំផន បានលើកឡើងថា ក្រុមសហព្រះរាជអាជ្ញាជ្រើសរើសយកតែអង្គហេតុណាដែលគាំទ្រ ឬស្របទៅតាមទស្សនៈរបស់ខ្លួនតែប៉ុណ្ណោះ ដែលអង្គហេតុទាំងនោះ ខុសពីទស្សនៈរបស់ក្រុមមេធាវីការពារក្តី ។ ទោះបីជាយ៉ាងណាក្តីមេធាវី អង់តា ហ្គីសេ ពុំបានបង្ហាញអំពីអង្គហេតុជាក់លាក់ដែលខ្លួនមានបំណងដាក់បញ្ចូលនៅក្នុងសំណុំរឿង០០២/០២ ឡើយ ដោយគ្រាន់តែបញ្ជាក់ថា ខ្លួននឹងដាក់សារណាជាលាយលក្ខណ៍អក្សរជូនអង្គជំនុំជម្រះ ដែលសារណានេះនឹងបញ្ជាក់អំពីទីតាំងឧក្រិដ្ឋកម្ម និងសាក្សីដែលត្រូវយកមកសួរដេញដោល ។ នៅក្នុងសេចក្តីកត់សម្គាល់របស់ខ្លួន មេធាវី អង់តា ហ្គី




ផ្ទះរបស់ តាម៉ុក មេបញ្ជាការមួយរូបរបស់ខ្មែរក្រហម នៅអន្លង់វែង ខេត្តឧត្តរមានជ័យ ។ សព្វថ្ងៃនេះ គឺជាទីតាំងប្រវត្តិ សាស្ត្រមួយនៅតំបន់អន្លង់វែងដែលខ្មែរក្រហមធ្លាប់កាន់កាប់ ។ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

សេ ធ្វើការផ្តោតយ៉ាងខ្លាំងអំពីការចាប់ផ្តើមសវនាការលើសំណុំរឿង០០២/០២ ។ តាមគោលជំហររបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន សំណុំរឿង០០២/០២ ត្រូវចាប់ផ្តើមជំនុំជម្រះបន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូលចេញសាលដីកាលើសំណុំរឿង០០២/០១រួចរាល់សិន ព្រោះសាលដីកានេះនឹងសម្រេចអំពីអង្គហេតុ និងទម្រង់នៃការទទួលខុសត្រូវរបស់ជនជាប់ចោទបានច្បាស់លាស់ ។ មេធាវីអះអាងថា ការអនុវត្តបែបនេះ នឹងធ្វើឲ្យសវនាការលើសំណុំរឿង០០២/០២ ដំណើរការបានលឿន និងមានប្រសិទ្ធភាព ។ អង់តា ហ្គីសេ ធ្វើការវាយប្រហារថា ក្រុមសហព្រះរាជអាជ្ញា និងក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានការប្រែក្រឡាស់គោលជំហរក្នុងការចាប់ផ្តើមសវនាការលើសំណុំរឿង០០២/០២ ហើយដែលការផ្លាស់ប្តូរនេះ "ហាក់ដូចជាប្រែប្រួលតាមបរិយាកាស ដូចជាថា ធ្វើយ៉ាងម៉េចបំពេញចិត្តអ្នកផ្តល់ជំនួយជាដើម" ។ ភ្លាមៗនោះ តំណាងសហព្រះរាជអាជ្ញា អន្តរជាតិ ឌេល លីសាក់ ធ្វើការឆ្លើយតបថា គោលជំហររបស់ក្រុមសហព្រះរាជអាជ្ញាពុំមានការប្រែប្រួលឡើយ ពោលគឺនៅតែមានបំណងឲ្យសំណុំរឿង០០២/០២ ចាប់ផ្តើមជំនុំជម្រះបន្ទាប់ពីសំណុំរឿង០០២/០១ ត្រូវបានជំនុំជម្រះចប់សព្វគ្រប់ដដែល ។ ការផ្លាស់ប្តូរគោលជំហររបស់ខ្លួននេះ ដោយសារអង្គជំនុំជម្រះតុលាការកំពូលបង្គាប់ឲ្យចាប់ផ្តើមធ្វើការជំនុំជម្រះលើសំណុំរឿង០០២/០២ឲ្យបានលឿនបំផុតតាម ដែលអាចធ្វើទៅបាន ។ មេធាវី ពេជ អង្គ បានសម្តែងការគាំទ្រចំពោះការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា និងបន្ថែមថា គប្បីអនុវត្តតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដើម្បីធ្វើឲ្យយ៉ាងណាឲ្យសំណុំរឿង០០២/០២ ឲ្យបានឆាប់រហ័ស ព្រោះទាំងជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីសុទ្ធសឹងតែមានវ័យចាស់ជរា ។

## ៣) ការពិភាក្សាអំពីកាលបរិច្ឆេទចាប់ផ្តើមសវនាការលើសំណុំរឿង០០២/០២

តាមការលើកឡើងរបស់ប្រធានអង្គជំនុំជម្រះចៅក្រម និល ណុន កាលបរិច្ឆេទនៃការចាប់ផ្តើម សវនាការលើសំណុំរឿង០០២/០២ មានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងការបង្កើត ឬមិនបង្កើតអង្គជំនុំជម្រះទី២ និងវិសាលភាពនៃសំណុំរឿង០០២/០២ ។ នៅក្នុងកិច្ចពិភាក្សាលើប្រធានបទនេះ ប្រធានអង្គជំនុំជម្រះស្នើឲ្យភាគីទាំងអស់ លើកឡើងអំពីលទ្ធភាពរបស់ខ្លួនក្នុងការចូលរួមសវនាការលើសំណុំរឿង០០២/០២ ពោលគឺថា តើភាគីនីមួយៗអាចមានលទ្ធភាពពេញលេញចូលរួមសវនាការដែរឬទេក្នុងករណីសំណុំរឿង០០២/០២ចាប់ផ្តើមដំណើរការ?

ឆ្លើយតបនឹងសំណួរនេះ សហព្រះរាជអាជ្ញា នីកូឡាស គុំចាន់ ផ្តល់ការបញ្ជាក់ថា ក្រុមសហព្រះរាជអាជ្ញានឹងមានលទ្ធភាពចូលរួមគ្រប់ពេល នៅពេលដែលសំណុំរឿង ០០២/០២ ចាប់ផ្តើមដំណើរការ ។ ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា ក៏ពុំមានបញ្ហាអ្វីដែរក្នុងការចូលរួមសវនាការលើសំណុំរឿង០០២/០២ ពោលគឺអាចចូលរួមសវនាការគ្រប់ពេលវេលា ។ ដោយឡែកក្រុមមេធាវីការពារក្តី ខៀវ សំផន បញ្ជាក់ថា ក្រុមរបស់ខ្លួនពុំមានភាពច្បាស់លាស់ឡើយអំពីបញ្ហានេះ ។ មេធាវីបញ្ជាក់ថា វាអាស្រ័យទៅលើចំនួនមនុស្សដែលត្រូវធ្វើការ និងចំនួនភ័ស្តុតាងដែលត្រូវពិនិត្យមើលនៅក្នុងសំណុំរឿង០០២/០២ ។

ទាក់ទងទៅនឹងកាលបរិច្ឆេទនៃការចាប់ផ្តើមសវនាការលើសំណុំរឿង០០២/០២ ក្រុមសហព្រះរាជអាជ្ញា និងក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំអង្គជំនុំជម្រះធ្វើសវនាការចាប់ពីចុងខែកុម្ភៈ ឆ្នាំ២០១៤ តទៅ ។ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា យល់ស្របចំពោះការកំណត់កាលបរិច្ឆេទនេះ ។ ប៉ុន្តែមេធាវី វិចទ័រ កូប៉េ បញ្ជាក់ថា គាត់ពុំមានសុទិដ្ឋិនិយមថា សវនាការនឹងអាចចាប់ផ្តើមនៅចុងខែកុម្ភៈ ឡើយ ព្រោះការកំណត់នេះពុំមានទិដ្ឋភាពពិតប្រាកដ ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានយល់ស្របចំពោះការលើកឡើងរបស់មេធាវី វិចទ័រ កូប៉េ ដែលថា សវនាការលើសំណុំរឿង០០២/០២ នឹងមិនអាចធ្វើទៅរួចនៅចុងខែកុម្ភៈ ឆ្នាំ២០១៤ ។ តាមគោលជំហររបស់មេធាវី អង់តា ហ្គីសេ អង្គជំនុំជម្រះសាលាដំបូងអាចធ្វើសវនាការលើសំណុំរឿង០០២/០២ លុះត្រាតែសំណុំរឿង០០២/០១ ត្រូវបានកាត់សេចក្តីចប់សព្វគ្រប់ ពោលគឺ ទាល់តែសាលក្រម ឬសាលដីកា លើសំណុំរឿង០០២/០១ចូលស្ថាពរ ។

# ផ្នែកទី២ ៖ អត្ថបទសិក្សាស្រាវជ្រាវ
# ការអនុវត្តវិធាននៃភស្តុតាងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

*លឹម ជ័យទ័ត្ត*

## *សេចក្តីផ្តើម*

នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌទាំងនៅតុលាការអន្តរជាតិ និងតុលាការក្នុងស្រុក ភស្តុតាងជាធាតុសំខាន់បំផុតដែលចៅក្រម ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវពឹងផ្អែកលើដើម្បីយកមកធ្វើការពិចារណា និងធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្តីរបស់ខ្លួន ។ ដើម្បីដាក់បុគ្គលណាម្នាក់ឲ្យទទួលខុសត្រូវព្រហ្មទណ្ឌចាំបាច់ត្រូវមានភស្តុតាងគ្រប់គ្រាន់ និងអាចគួរឲ្យជឿជាក់បាន ដើម្បីបង្ហាញថាបុគ្គលរូបនោះ ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ ។ ភស្តុតាងដែលនឹងត្រូវលើកយកមកបង្ហាញនៅក្នុងតុលាការចាំបាច់ត្រូវតែមានភាពជាប់ពាក់ព័ន្ធរវាងបុគ្គលដែលជាអ្នកប្រព្រឹត្ត និងឧក្រិដ្ឋកម្មដែលបានកើតឡើង ជាពិសេសភស្តុតាងនោះត្រូវតែបង្ហាញឲ្យចៅក្រមមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

ដើម្បីធានាថា ភស្តុតាងដែលនឹងត្រូវដាក់ជូនតុលាការដើម្បីធ្វើការពិចារណា ជាភស្តុតាងដែលមានភាពជាប់ពាក់ព័ន្ធ និងមានភាពគួរឲ្យជឿជាក់បាន ចាំបាច់ត្រូវមាន វិធាននៃភស្តុតាង ។ វិធាននៃភស្តុតាង បានកំណត់អំពីឆន្ទានុសិទ្ធិរបស់ចៅក្រម ឬក្រុមប្រឹក្សាជំនុំជម្រះ ក្នុងការសម្រេចទទួលយក ឬបដិសេធរាល់ភស្តុតាងទាំងឡាយដែលភាគីនៃរឿងក្តីដាក់ជូនតុលាការ ដោយផ្អែកលើភាពជាប់ពាក់ព័ន្ធ និងភាពគួរឲ្យជឿជាក់បាននៃភស្តុតាងទាំងនោះ ។ វិធាននៃភស្តុតាងអាចជះឥទ្ធិពលទៅដល់លទ្ធផលនៃការសម្រេចចិត្តរបស់តុលាការ ព្រោះវិធាននេះត្រូវបានយកទៅអនុវត្តសម្រាប់គ្រប់គ្រងលើភស្តុតាងទាំងឡាយដែលប្រើប្រាស់ដោយព្រះរាជអាជ្ញា ឬមេធាវីការពារក្តីឲ្យជនជាប់ចោទ ។

វិធាននៃភស្តុតាងដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា នៅត្រង់មាត្រា៣២១[១] ហាក់បីដូចជាពុំបានចែងលម្អិតអំពីនីតិវិធីនៃការទទួលយកភស្តុតាង ហើយអត្ថន័យនៃវិធាននេះទៀតសោត នៅមានលក្ខណៈចង្អៀត ពុំទាន់អាចយកទៅអនុវត្តបាននៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលមានលក្ខណៈស្មុគស្មាញ និងធំធេង ដូចជាករណីឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហមដែលមានភស្តុងតាងយ៉ាងច្រើនលើសលុប ដែលដាក់ជូនដោយភាគី រង់ចាំអង្គជំនុំជម្រះធ្វើការវាយតម្លៃអំពីភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿជាក់បាន ។ ផ្ទុយពីក្រមនីតិវិធីព្រហ្មទណ្ឌ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅត្រង់មាត្រា៨៧ស្តីពីវិធាននៃភស្តុតាងបានចែងលម្អិតអំពីគោលការណ៍នីតិវិធីនៃការទទួលយកភស្តុតាងដាក់ចូលក្នុងសំណុំរឿង និងបុព្វសិទ្ធិរបស់អង្គជំនុំជម្រះក្នុងការវាយតម្លៃអំពីតម្លៃ និងទម្ងន់នៃភស្តុតាង ។[២] ដោយសារតែភស្តុតាងនៃឧក្រិដ្ឋកម្មដែលកើតឡើងក្នុងរបបខ្មែរក្រហម មានចំនួនច្រើនលើសលុប ដូច្នេះការចែងលម្អិតអំពីវិធាននៃភស្តុតាងនឹងអាចអនុញ្ញាតឲ្យអង្គជំនុំជម្រះងាយស្រួលក្នុងការកំណត់ថា តើភស្តុតាងណាដែលមានភាពជាប់ពាក់ព័ន្ធ និងមានភាពគួរឲ្យជឿជាក់បាន និងភស្តុតាងប្រភេទណាគួរត្រូវបានបដិសេធ ។

ចំណុចខាងក្រោម នឹងបង្ហាញអំពីការអនុវត្តវិធាននៃភស្តុតាងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងប្រភេទនៃភស្តុតាងដែលមាននៅក្នុងសំណុំរឿង ។

## ១) ការទទួលយកភស្តុតាង

វិធាន៨៧(១) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា «លើកលែងតែមានបញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវទទួលយក» ។ វិសាលភាពនៃគោលការណ៍ទូទៅនេះត្រូវបានបញ្ជាក់ដោយវិធាន៨៧(២) នៃវិធានផ្ទៃក្នុងដែលបានចែងបន្ថែមថា «សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវតែផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះ

ត្រូវឆ្លងកាត់ការដេញដោល» ។ វិធាន៨៧(៣) នៃវិធានផ្ទៃក្នុង បានបង្ហាញថា ភស្តុតាងដែលមាននៅក្នុងសំណុំរឿងត្រូវបានចាត់ទុកថាបានលើកឡើង នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ឬត្រូវបានអាននៅក្នុងសវនាការ ។[៣]

ទោះបីជាពាក្យពេចន៍នៃវិធាន៨៧(៣) សំដៅទៅលើ«ភស្តុតាង ។ ភស្តុតាងចម្លង និងភស្តុតាងប្រយោល អាចត្រូវបានទទួលយកទៅពិចារណាដោយអង្គជំនុំជម្រះ នៅពេលដែលភស្តុតាងទាំងនោះមានភាពជាប់ពាក់ព័ន្ធ និងមានតម្លៃអាចជឿជាក់បាន ប៉ុន្តែអង្គជំនុំជម្រះនឹងធ្វើការ ពិចារណាជាពិសេសថា តើជនជាប់ចោទអាចតទល់នឹងប្រភពភស្តុតាងបែបនោះបានដែរឬយ៉ាងណា[៥] ។ ទោះបីជាយ៉ាងណា អង្គជំនុំជម្រះអាចបដិសេធមិនយកមកធ្វើជា



ចៅក្រម និងសហព្រះរាជអាជ្ញា ក្នុងសាលសវនាការ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

តាងដែលយកមកពីក្នុងសំណុំរឿងក៏ដោយ» ក៏ខ្លឹមសារទូទៅនៃអនុវិធានក្នុងវិធាននេះបង្ហាញឲ្យឃើញច្បាស់ថា សម្ភារទាំងអស់ដែលមាននៅក្នុងសំណុំរឿង គឺមិនមែនជា«ភស្តុតាង»ទេ ប្រសិនបើសម្ភារទាំងនោះមិនត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ (ដូចជា ត្រូវបានសង្ខេប ត្រូវបានអាន ឬអាចត្រូវបានកំណត់អត្តសញ្ញាណ) ។ បន្ថែមពីលើនេះ អង្គជំនុំជម្រះអាចទទួលយកភស្តុតាងថ្មីដែលមិនមាននៅក្នុងសំណុំរឿងតាមឆន្ទានុសិទ្ធិ ឬតាមសំណើរបស់ភាគី ។[៤]ម្យ៉ាងវិញទៀត ដើម្បីអាចយកមកប្រើប្រាស់ជាភស្តុតាង សម្ភារដែលមាននៅក្នុងសំណុំរឿង ត្រូវតែបំពេញលក្ខខណ្ឌច្បាស់លាស់នៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាននៃភស្តុតាងនូវសម្ភារណាមួយ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដែលមានចែងក្នុងវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង (ដូចជា ភាពមិនជាប់ពាក់ព័ន្ធ ភាពមិនសមស្របសម្រាប់បញ្ជាក់ពីអង្គហេតុដែលចោទប្រកាន់ ភស្តុតាងដែលមិនអាចរកបានក្នុងរយៈពេលសមស្រប ឬដោយសារតែអត្ថិភាពនៃការរំលោភបំពានលើបទដ្ឋានច្បាប់ជាសារវន្តដែលពាក់ព័ន្ធនឹងវិធាននៃភស្តុតាង) ។[៦]

ដូច្នេះ ដើម្បីអាចយកមកប្រើប្រាស់ជាភស្តុតាងបានសម្ភារដែលមាននៅក្នុងសំណុំរឿងត្រូវបំពេញឲ្យបាននូវបទដ្ឋានអប្បរមានៃភាពជាប់ពាក់ព័ន្ធ និងភាពគួរឲ្យជឿជាក់បាន ដែលចាំបាច់ដើម្បីឲ្យសម្ភារទាំងនោះអាចដាក់ដេញដោលបាននៅចំពោះមុខអង្គជំនុំ

ជម្រះ ។ បន្ទាប់ពីសម្ភារទាំងនោះត្រូវ បានដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះ ភាពអាចជឿជាក់បាននៃភស្តុតាង និងទម្ងន់នៃភស្តុតាងនឹងត្រូវវាយតម្លៃដោយអង្គជំនុំជម្រះ[៧] ប្រសិនបើភស្តុតាងទាំងនោះមានប្រើប្រាស់នៅក្នុងសាលក្រម ប៉ុន្តែពុំមែនវាយតម្លៃនៅក្នុងដំណាក់កាលទទួលយកឡើយ ។ នៅពេលមានការវាយតម្លៃលើភស្តុតាង ប្រសិនបើអង្គជំនុំជម្រះមាន *"ភាពសង្ស័យអំពីពិរុទ្ធភាព"* របស់ជនជាប់ចោទ ការបកស្រាយត្រូវតែធ្វើឡើងនៅក្នុងន័យដែលផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ ។[៨] ការតម្រូវដូច្នេះ គឺដោយសារគោលការណ៍ ច្បាប់ និងវិធាន៨៧(១) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានកំណត់យ៉ាងច្បាស់ថា *"ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ"* ។

## ២) ប្រភេទនៃភស្តុតាងដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ

សំណុំរឿងក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាសំណុំរឿងដែលមានលក្ខណៈពិសេស ដោយសារតែតុលាការនេះពុំមែនបង្កើតឡើងក្នុងគោលបំណងដើម្បីកាត់ទោសជនដៃដល់ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅអំឡុងពេលនៃរបបខ្មែរក្រហមទេ ប៉ុន្តែបង្កើតឡើងដើម្បីកាត់ទោសជនពីរប្រភេទ គឺមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដូច្នេះ ភស្តុតាងដែលត្រូវយកមកបង្ហាញនៅចំពោះមុខតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ពុំមែនភស្តុតាងជាវត្ថុដែលជនដៃដល់យកទៅប្រព្រឹត្តឧក្រិដ្ឋកម្ម (ដូចជា កាំភ្លើង កាំបិត ពូថៅ ដំបង...) ដូចរឿងក្តីព្រហ្មទណ្ឌនៅតុលាការក្នុងស្រុកទេ ។ ភស្តុតាងដែលត្រូវលើកយកមកសំអាងដើម្បីកាត់ទោសជនទាំងពីរប្រភេទខាងលើ ភាគច្រើនជាប្រភេទឯកសារដែលនៅសេសសល់ពីរបបកម្ពុជាប្រជាធិបតេយ្យ មានដូចជា ឯកសារជាក្រដាស រូបថត ខ្សែវីដេអូ និងបទសម្ភាសន៍ ដែលបង្ហាញអំពីការទទួលខុសត្រូវ និងខ្សែសង្វាក់នៃការបញ្ជារបស់មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រៅពីនេះសក្ខីកម្មរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលផ្តល់ជូនចៅក្រមស៊ើបអង្កេតនៅក្នុងដំណាក់កាលស៊ើបអង្កេត និងនៅក្នុងដំណាក់កាលអង្គជំនុំជម្រះសាលាដំបូង ក៏ជាប្រភពភស្តុតាងដ៏សំខាន់ដែលត្រូវបានប្រើប្រាស់ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ដោយសារអ្នកទាំងនោះជាអ្នកដែលបានឆ្លងកាត់ បានឃើញ បានជួបប្រទះ និងយល់ដឹងយ៉ាងច្បាស់ពីព្រឹត្តិការណ៍ដែលបានកើតឡើង ។ ដូចគ្នានេះដែរ ចម្លើយតបនានារបស់ជនជាប់ចោទអាចបង្កើតបានជាភស្តុតាង ដែលតម្លៃនៃភស្តុតាងនេះ ត្រូវបានយកទៅពិចារណាដោយអង្គជំនុំជម្រះ ។[៩] ទោះបីជាយ៉ាងណា ដើម្បីឲ្យសក្ខីកម្មរបស់សាក្សី និងអ្នកជំនាញ មានតម្លៃ និងទម្ងន់ជាភស្តុតាង ការផ្តល់សក្ខីកម្មនោះចាំបាច់ត្រូវតែឆ្លងកាត់ការធ្វើសម្បថមុនពេលចូលផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ។ រីឯដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទ ច្បាប់ពុំបានតម្រូវឲ្យធ្វើសម្បថនៅមុនពេលចូលផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះទេ ដោយសារតែទាំងដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទ សុទ្ធតែជាភាគីនៃរឿងក្តី ហើយសក្ខីកម្មដែលត្រូវបានផ្តល់នៅតែមានតម្លៃ និងទម្ងន់ជាភស្តុតាង ។[១០]

ភាគច្រើនលើសលុបនៃឯកសារភស្តុតាងទាំងអស់ គឺបន្សល់ទុកពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយត្រូវបានប្រមែប្រមូលចងក្រង និងថែរក្សាទុកដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រើប្រាស់ឯកសារទាំងនោះធ្វើជាភស្តុតាងដោយចោទប្រកាន់មេដឹកនាំ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ការទទួលយកឯកសារទាំងនោះមកធ្វើជាភស្តុតាង ពុំមែនធ្វើឡើងតាមរយៈការសន្មតទេ អង្គជំនុំជម្រះបានពិនិត្យ និងពិចារណាយ៉ាងយកចិត្តទុកដាក់លើខ្សែសង្វាក់នៃការរក្សាទុកឯកសារ និងយថាភាពនៃឯកសារ ដោយបានកោះអញ្ជើញប្រធាន និងអនុប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីបញ្ជាក់លម្អិតអំពីប្រភព ខ្សែសង្វាក់នៃការរក្សាទុក និងយថាភាពនៃឯកសារ ត្រូវបានប្រើប្រាស់ធ្វើជាភស្តុតាងទាំងអស់នោះ ។ ក្រៅពីនេះ អង្គជំនុំជម្រះក៏បានកោះហៅសាក្សីដែលជាអ្នកថតរូប និងជាអ្នកកាសែតជនជាតិអាមេរិកាំង ដែលបានផ្តិតយករូបភាពជាច្រើនអំពីស្ថានភាព និងព្រឹត្តិការណ៍ក្នុងទីក្រុងភ្នំពេញ នៅមុន និងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៩ មកផ្តល់សក្ខីកម្ម ដើម្បីបញ្ជាក់អំពីរូបថតមួយចំនួនដែលបានថតនៅទីតាំងផ្សេងៗ បន្ទាប់ពីខ្មែរក្រហមចូលមកដល់

ទីក្រុងភ្នំពេញ ។ ទោះបីជាយ៉ាងណា សាក្សីពុំចាំបាច់ត្រូវតែជាអ្នកថតរូបនោះទេ មានសាក្សីមួយចំនួនត្រូវបានកោះហៅចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីពិពណ៌នាពីព្រឹត្តិការណ៍ និងបទពិសោធន៍ផ្ទាល់ខ្លួន និងត្រូវបានស្នើឲ្យធ្វើការបញ្ជាក់ថា តើរូបថតដែលមាននៅក្នុងសំណុំរឿងពិតជា ឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ដែលបានកើតឡើងដែរឬយ៉ាងណា ។

### ៣) ការដាក់ភ័ស្តុតាងថ្មី

នៅមុនពេលបើកសវនាការបឋម អង្គជំនុំជម្រះសាលាដំបូងតែងបានបង្គាប់ឲ្យភាគីទាំងអស់ត្រូវដាក់ឯកសារ និង/ឬបញ្ជីនានាដែលរៀបរាប់អំពីភ័ស្តុតាងជូនអង្គជំនុំជម្រះឲ្យបានតាមពេលកំណត់ ដូចមានចែងនៅក្នុងវិធាន៨០(៣) នៃវិធានផ្ទៃក្នុង[១១] ។ ភ័ស្តុតាង និងបញ្ជីឯកសារដែលពុំត្រូវបានដាក់ តាមពេលវេលាកំណត់ នឹងត្រូវបដិសេធដោយអង្គជំនុំជម្រះសាលាដំបូង លើកលែងតែភ័ស្តុតាងនោះជាភ័ស្តុតាងថ្មី ។

ភ័ស្តុតាងថ្មី គឺជាភ័ស្តុតាងដែលពីមុនពុំមាននៅក្នុងសំណុំរឿង និង/ឬពុំមាននៅក្នុងបញ្ជីរបស់ភាគី ដូចដែលមានចែងនៅក្នុងវិធាន៨០(៣) នៃវិធានផ្ទៃក្នុង ។[១២] ដើម្បីអាចដាក់ភ័ស្តុតាងថ្មីចូលក្នុងសំណុំរឿង ភាគីទាំងអស់ចាំបាច់ត្រូវតែគោរពតាមលក្ខខណ្ឌនៃភាពអាចទទួលយកបានដ៏តឹងរ៉ឹងនៃវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានចែងយ៉ាងច្បាស់ថា ភាគីត្រូវតែបង្ហាញថា ខ្លួនបានយកចិត្តទុកដាក់គ្រប់គ្រាន់ក្នុងការស្វែងរក និងបង្ហាញភ័ស្តុតាងដែលមិនអាចរកបានមុនពេលបើកការជំនុំជម្រះ ។ តាមរយៈសំណើសុំដែលមានសំអាងហេតុ ភាគីត្រូវបង្ហាញថា ភ័ស្តុតាងថ្មីទាំងនេះពុំអាចរកបាននៅមុនពេលបើកការជំនុំជម្រះ និង/ឬ មិនអាចរកឃើញ និងពុំត្រូវបានផ្តល់ឲ្យនៅមុនពេល ទោះបីជាបានខិតខំយកចិត្តទុកដាក់ក្នុងការស្វែងរកហើយក៏ដោយ ។ ភ័ស្តុតាងថ្មី ត្រូវតែអាចនាំដល់ការលាតត្រដាងពីការពិត និងត្រូវបំពេញលក្ខខណ្ឌនៃវិធាន៨៧(៣) នៃវិធានផ្ទៃក្នុងដែរ ។[១៣]

### ៤) ការវិភាគលើឯកសារភ័ស្តុតាងជាក់លាក់ដោយអង្គជំនុំជម្រះសាលាដំបូង

បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទទួលយកកំណត់ហេតុស្តាប់ចម្លើយ ជាលាយលក្ខណ៍អក្សរ និងប្រតិចារឹករបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ជំនួសឲ្យការផ្តល់សក្ខីកម្ម ផ្ទាល់មាត់ ដោយមិនចាំបាច់ផ្តល់ឱកាសឲ្យតទល់គ្នា ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា និង ខៀវ សំផន បានធ្វើការជំទាស់ជាបន្តបន្ទាប់ ។ ការជំទាស់នោះ ផ្តោតជាពិសេសលើឯកសារស្តីពីកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹក ដែលបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដោយមិនចាំបាច់ស្តាប់សក្ខីកម្មសាក្សីនៃកំណត់ហេតុទាំងអស់នោះនៅក្នុងសវនាការ ។[១៤] បន្ទាប់ពីទទួលបានពាក្យបណ្តឹងជំទាស់ពីមេធាវីការពារក្តី



ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចែកឯកសារជូននិស្សិត
ការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ (ប

អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចទាក់ទងនឹងភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកនៅក្នុងសំណុំរឿង០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ នៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះបានវិភាគលើភ័ស្តុតាងជាក់លាក់ មួយចំនួន ដូចខាងក្រោម ៖

### ក) ភ័ស្តុតាងជាកំណត់ហេតុស្តាប់ចម្លើយសាក្សី និងប្រតិចារឹកដែលបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ

ចំពោះកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹក ដែលនឹងបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើកលែងតែមានអញ្ញត្រកម្មតិចតួចប៉ុណ្ណោះ ត្រូវចាត់ទុកថា "មិនអាចអនុញ្ញាតឲ្យយកមកប្រើប្រាស់តាមច្បាប់ឡើយ" ប្រសិនបើក្រុមមេធាវីការពារក្តី ពុំទទួលបានឱកាសសួរដេញ



...ាសកលវិទ្យាល័យស្វាយរៀង ក្នុងការធ្វើបទបង្ហាញអំពីដំណើរការវិវត្ត ...ណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដោលអ្នកបានផ្តល់ចម្លើយទាំងនេះនៅក្នុងតុលាការ ។ ទោះបីជាយ៉ាងណា ក្នុងករណីដែលកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំងនោះមានភាពជាប់ពាក់ព័ន្ធសម្រាប់បង្ហាញបញ្ហាផ្សេងៗក្រៅពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដូចបានចោទប្រកាន់ ហើយបានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង និងអាចជាប្រយោជន៍នៃយុត្តិធម៌ ភ័ស្តុតាងបែបនេះអាចនឹងត្រូវទទួលយក ។[១៥]

កត្តានានាដែលគាំទ្រដល់ការទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹក ជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ រួមមាន ការពុំមានឱកាសពិតប្រាកដសម្រាប់តទល់គ្នាចំពោះមុខ (ដោយសារមរណភាពការមិនមានលទ្ធភាពផ្នែកសុខភាពក្នុងការផ្តល់សក្ខីកម្មដោយផ្ទាល់មាត់ ឬពុំមានលទ្ធភាព ទោះបីជាបានខិតខំយ៉ាងយកចិត្តទុកដាក់ក្នុងការស្វែងរកអ្នកផ្តល់ចម្លើយនោះក៏ដោយ) លក្ខណៈបញ្ជាក់នៃភ័ស្តុតាង និងករណីថា តើភ័ស្តុតាងទាំងនោះបានបង្ហាញពីធាតុផ្សំអប្បបរមានៃឧក្រិដ្ឋកម្មអន្តរជាតិ (ដូចជា លក្ខណៈជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំរាលដាលនៃការវាយប្រហារ) មូលដ្ឋានឧក្រិដ្ឋកម្ម ផលប៉ះពាល់លើជនរងគ្រោះ សាវតារប្រវត្តិសាស្ត្រ ឬរចនាសម្ព័ន្ធរដ្ឋបាល ។[១៦]

អង្គជំនុំជម្រះនឹងធ្វើការពិចារណាអំពីតម្លៃ និងទម្ងន់ នៃកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹក ដែលត្រូវបានទទួលយកជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់ នៅពេលដែលជនជាប់ចោទពុំមានឱកាសសម្រាប់តទល់ចំពោះមុខម្ចាស់សក្ខីកម្មទាំងនោះ ។[១៧]

ទោះបីជាយ៉ាងណា គ្មានអ្វីអាចរារាំងការទទួលយកកំណត់ហេតុស្តាប់ចម្លើយ ឬប្រតិចារឹកដែលអាចមានភ័ស្តុតាងពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់នោះទេ នៅពេលឯកសារទាំងនោះគ្រាន់តែត្រូវបានស្នើឡើងដើម្បីយកមកធ្វើជាមូលដ្ឋានសម្រាប់គោលបំណងនានា ក្រៅពីការបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ រួមទាំងភាពអាចទុកចិត្តបាននៃភ័ស្តុតាងផ្សេងៗទៀត ដែលមាននៅក្នុងខ្សែអាត់ថតសំឡេង និងវីដេអូ ។[១៨]

### ខ) កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹករបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ

នៅពេលសាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី មកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ពេលនោះមេធាវីការពារក្តីនឹងមានឱកាសក្នុងការសួរតទល់ជាមួយពួកគាត់ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹក ។ ដូច្នេះ ចម្លើយរបស់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលចូលមកផ្តល់សក្ខីកម្មនោះ ពុំចាំបាច់បំពេញតាមលក្ខណៈវិនិច្ឆ័យ ដូចមានកំណត់នៅក្នុងសេចក្តីសម្រេចលើ

កំណត់ហេតុស្តាប់ចម្លើយទេ ។ ចម្លើយទាំងនោះគ្រាន់តែត្រូវបំពេញតាមលក្ខខណ្ឌតម្រូវនៃភាពអាចទទួលយកបានជាទូទៅ ដូចមានចែងក្នុងវិធាន៨៧(៣) នៃវិធានផ្ទៃក្នុងក៏បានដែរ ។[១៩]

កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹករបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះត្រូវបានសន្មតថា មានភាពជាប់ពាក់ព័ន្ធ និងអាចជឿជាក់បានជាបឋម ។ បន្ថែមពីលើនេះ ដើម្បីជាប្រយោជន៍យុត្តិធម៌ កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹក នឹងត្រូវយកមកពិចារណាជាមួយនឹងភស្តុតាងដទៃទៀតរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ។[២០]

### គ) កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដែលបានទទួលមរណភាព

យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបបង្ហាញថា សិទ្ធិក្នុងការពិនិត្យលើសាក្សីដែលជាផ្នែកនៃសិទ្ធិក្នុងការទទួលបាននូវការកាត់ទោសដោយយុត្តិធម៌ ជាធម្មតាបានសន្មតជាមុនថា ភស្តុតាងនឹងត្រូវនាំយកមកបង្ហាញនៅក្នុងសវនាការសាធារណៈ ដោយមានវត្តមានរបស់ជនជាប់ចោទ ដែលអាចមើលឃើញការជជែកតទល់គ្នា ។ នៅពេលមានការលើកលែងចំពោះគោលការណ៍ទូទៅនេះ តាមវិធានទូទៅជនជាប់ចោទត្រូវបានផ្តល់នូវឱកាសគ្រប់គ្រាន់ និងសមស្របដើម្បីធ្វើការជំទាស់ និងអាចសួរសំណួរទៅសាក្សីដែលប្រឆាំងនឹងខ្លួនទាំងនៅពេលផ្តល់ចម្លើយ ឬនៅដំណាក់កាលបន្ទាប់ទៀត ។[២១]

តុលាការឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗទៀតអនុញ្ញាតឲ្យមានការប្រើប្រាស់ភស្តុតាងនៅក្នុងទម្រង់ ជាកំណត់ហេតុលាយលក្ខណ៍អក្សររបស់សាក្សីដែលបានទទួលមរណភាព ឬសាក្សីដែលគេមិនអាចរកឃើញដោយការព្យាយាមសមរម្យ នៅពេលដែលភស្តុតាងនៅបានបំពេញលក្ខខណ្ឌមួយចំនួន ។ កត្តាដែលត្រូវពិចារណាថាតើត្រូវទទួលយកភស្តុតាងបែបនេះ ឬមិនទទួលយកនោះ រួមមានកាលៈទេសៈ ដែលចម្លើយនោះត្រូវបានធ្វើ និងត្រូវបានកត់ត្រាថាតើចម្លើយបើកផ្លូវឲ្យមានការសួរដេញដោលភាគីប្រឆាំង ដែលកំពុងប្រើប្រាស់ភស្តុតាងនេះដើម្បីចោទប្រកាន់ឬទេ និងថា តើចម្លើយនោះទាក់ទងនឹងព្រឹត្តិការណ៍ដែលនាំឲ្យមានភស្តុតាងផ្សេងទៀតដែរឬទេ ។ នៅពេលដែលភស្តុតាងឈានទៅរកការបង្ហាញពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ ដូចដែលត្រូវបានចោទប្រកាន់នោះ នេះគឺជាកត្តាដែលប្រឆាំងនឹងភាពអាចទទួលយកបាននៃភស្តុតាងបែបនេះ ឬក៏ជាផ្នែកនៃភស្តុតាងនោះ ។[២២]

នៅក្នុងបរិបទនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលមរណភាព គឺ«អាចទទួលយកបាន»ទាំងសម្រាប់គោលបំណងក្នុងការបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់ ។ ប៉ុន្តែកំណត់ហេតុស្តាប់ចម្លើយទាំងអស់នោះចាំបាច់ត្រូវតែមានភាពជាប់ពាក់ព័ន្ធ និងអាចជឿជាក់បាន ជាបឋម ឬបានគោរពតាមលក្ខខណ្ឌនៃវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង ។[២៣]

ទោះបីជាកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលមរណភាពអាចទទួលយកបានដើម្បីបង្ហាញអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទដូចបានចោទប្រកាន់ក៏ដោយ ក៏កំណត់ហេតុស្តាប់ចម្លើយទាំងអស់នោះ អាចមានតម្លៃជាភស្តុតាងតិចតួច ហើយការសម្រេចឲ្យជាប់ពិរុទ្ធភាពមិនអាចផ្អែកទាំងស្រុង ឬជាសំខាន់លើកំណត់ហេតុស្តាប់ចម្លើយទាំងនោះឡើយ ។[២៤]

ទោះបីស្ថិតក្នុងករណីណាក៏ដោយ ប្រសិនបើមានការជំទាស់ពីសំណាក់មេធាវីការពារក្តីទៅលើគុណៈវិនិច្ឆ័យនៃការទទួលយកភស្តុតាង ការជំទាស់នោះនឹងត្រូវទទួលបានការពិចារណាពីអង្គជំនុំជម្រះ នៅពេលមានការវាយតម្លៃពីតម្លៃ និងទម្ងន់ ប្រសិនបើកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹកទាំងអស់ ដែលបានដាក់ដេញដោលនៅចំពោះមុខអង្គជំនុំជម្រះត្រូវបានដាក់បញ្ចូលទៅក្នុងសាលក្រម ។

### សន្និដ្ឋាន

សំណុំរឿង០០១ បានបិទបញ្ចប់ជាស្ថាពរ រីឯសវនាការលើសំណុំរឿង០០២ ដំណាក់កាលទី១ បានបិទបញ្ចប់ និងរង់ចាំការចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលរំពឹងថានឹងចេញនៅក្នុងអំឡុងឆមាសទី១ ឆ្នាំ២០១៤ ។ ការអនុវត្តវិធាននៃភស្តុតាងនៅក្នុងបរិបទនៃសំណុំរឿងក្តីស្មុគស្មាញ នៅអង្គជំនុំ

ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងក្លាយជាបទពិសោធន៍ និងគំរូសម្រាប់ការអនុវត្តនីតិវិធីទាក់ទងនឹងវិធានភស្តុតាងនៅក្នុងតុលាការក្នុងស្រុក ។ នាពេលអនាគត ការធ្វើវិសោធនកម្មលើវិធាននៃភស្តុតាង ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជាគួរតែត្រូវបានធ្វើឡើងដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកអនុវត្តច្បាប់អាចអនុវត្តវិធាននេះប្រកបដោយប្រសិទ្ធិភាពតាមគំរូបទដ្ឋានអន្តរជាតិ ។

១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៣២១ (ការវាយតម្លៃលើភស្តុតាងដោយតុលាការ) បានចែងទាក់ទងនឹងវិធាននៃភស្តុតាងថា ៖

- «លើកលែងបទបញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌ អាចជូនបានដោយសេរី ។ តុលាការថ្លឹងថ្លែង ដោយឥតស្បូរបិត្ត អំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន ។

- តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ ។

- ការសារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង ។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភស្តុតាងទេ ។

- ការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួនមិនអាចយកមកធ្វើជាភស្តុតាងបានឡើយ ។»

២ វិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវិសោធនកម្មលើកទី៨ ។

វិធាននៃភស្តុតាង ៖

១) លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក ។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

២) សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែក



មេធាវី សុន អារុណ និង នួន ជា នៅក្នុងសាលសវនាការ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

លើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល ។

៣) អង្គជំនុំជម្រះសាលាដំបូង ធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ប្រសិនបើភាគីយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬប្រសិនបើអង្គជំនុំជម្រះខ្លួនឯងយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខភាគី ។ ភស្តុតាងដែលមាននៅក្នុងសំណុំរឿងត្រូវបានចាត់ទុកថា បានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬភាគី បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេបត្រូវបានអាន ឬត្រូវបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងសមស្របក្នុងសវនាការ ។ អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាងបើយល់ឃើញថា ៖

ក) មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា

ខ) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ

គ) មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង

ឃ) ច្បាប់មិនអនុញ្ញាត ឬ

ង) មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍ ។

៤) ក្នុងអំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើសុំរបស់ភាគីអង្គជំនុំជម្រះ អាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឲ្យបានច្បាស់ ។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន៨៧(៣) ខាងលើ ។ ភាគីដែលស្នើសុំត្រូវតែធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ ។

៥) អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការថ្លឹងថ្លែងពិចារណានូវចម្លើយសារភាព ដូចគ្នានឹងប្រភេទនៃភស្តុតាងដទៃទៀតដែរ ។

៦) ក្នុងករណីដែលសហព្រះរាជអាជ្ញា និងជនជាប់ចោទព្រមព្រៀងគ្នាថា អង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានជំទាស់ទេ នោះអង្គជំនុំជម្រះអាចចាត់ទុកថា អង្គហេតុនោះត្រូវបានបញ្ជាក់ដោយភស្តុតាង ។

៧) ការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវី គឺជាបុព្វសិទ្ធិពិសេស និងមិនអាចយកមកធ្វើជាភស្តុតាងបានឡើយ ។

៨) ប្រធានអង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យនាំយកវត្ថុតាងមកបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះបាន ។

៣ សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង, ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០០៩, កថាខណ្ឌ៥, ឯកសារE43/4 ។

៤ សេចក្តីសម្រេចអំពីភាពអាចទទួលយកបាននៃភស្តុតាងថ្មី និងសេចក្តីណែនាំទាំងអស់, ឯកសារ E5/10/2 ថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩, កថាខណ្ឌ៦ ។ [បន្ទាប់ពីនេះនឹងហៅថា សេចក្តីសម្រេចអំពីភាពអាចទទួលយកបាននៃភស្តុតាងថ្មី] ។ សូមមើលផងដែរ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង, សំណុំរឿង០០១ ករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, ឯកសារE188, កថាខណ្ឌ៤០ ។ [បន្ទាប់ពីនេះនឹងហៅថា សាលក្រម ឌុច]

៥ សាលក្រម ឌុច ។ កថាខណ្ឌ៤៣ ។

៦ សេចក្តីសម្រេចអំពីភាពអាចទទួលយកបាននៃភស្តុតាងថ្មី ។ កថាខណ្ឌ៦ ។

៧ ដដែលដូចខាងលើ ។ កថាខណ្ឌ៧ ។

៨ សាលក្រម ឌុច, កថាខណ្ឌ៤៥ ។

៩ សាលក្រម ឌុច ។ កថាខណ្ឌ៥០ ។

១០ វិធាន២៣(៤) នៃវិធានផ្ទៃក្នុង («ដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវបានគេសួរដូចជាសាក្សីធម្មតាក្នុងសំណុំរឿងតែមួយនោះទេ ហើយស្របតាមវិធាន៦២ ដែលទាក់ទងនឹងដីកាចាត់ឲ្យ

ស៊ើបសួរដដែល អាចត្រូវបានគេស្តាប់ចម្លើយតែប៉ុណ្ណោះ ដោយស្ថិតក្រោមលក្ខខណ្ឌដូចគ្នាទៅនឹងជនត្រូវចោទ ឬជនជាប់ចោទដែរ») ។ សូមមើលផងដែរ សាលក្រម ឌុច, កថាខណ្ឌ៥១-៥២ ។ សូមអានបន្ថែម មាត្រាស្រដៀងគ្នា នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១៥៦ (សាក្សីមិនស្បថ), មាត្រា៣១២ (វិសមតិភាពរវាងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី និងឋានៈជាសាក្សី), មាត្រា៣២៦ (ការស្តាប់ចម្លើយរបស់ភាគី), មាត្រា៣២៧ (ការជំទាស់ទៅនឹងការស្តាប់ចម្លើយរបស់សាក្សី) ។

១១ វិធាន៨០(៣) ចែងថា ៖ អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឲ្យភាគីទាំងឡាយដាក់ឯកសារតាមពេលកំណត់មុនពេលសវនាការបឋម រួមទាំងឯកសារខាងក្រោម ៖

ក) បន្ថែមទៅនឹងបញ្ជីឈ្មោះសាក្សី ដែលមានយោងក្នុងវិធាន ៨០ នៃវិធានផ្ទៃក្នុង ៖

១) សេចក្តីសង្ខេបអង្គហេតុ ដែលសាក្សីគ្រប់រូបរំពឹងថានឹងធ្វើសក្ខីកម្ម ។ អនុលោមតាមវិធានការណ៍ការពារណាមួយ ដែលអាចត្រូវចេញសេចក្តីសង្ខេបគួរមានលក្ខណៈរៀបរាប់គ្រប់គ្រាន់ ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូង និងភាគីដទៃទៀតវាយតម្លៃខ្លស់ និងយល់បាននូវលក្ខណៈ និងខ្លឹមសារនៃការធ្វើសក្ខីកម្ម ដែលបានស្នើសុំធ្វើនោះ ។

២) ចំណុចនានានៃការចោទប្រកាន់ ដែលសាក្សីគ្រប់រូបរំពឹងថានឹងធ្វើសក្ខីកម្ម រួមទាំងកថាខណ្ឌ និងបទចោទជាក់លាក់ ។ និង

៣) ការប៉ាន់ស្មានអំពីរយៈពេលដែលតម្រូវឲ្យសាក្សីម្នាក់ៗធ្វើសក្ខីកម្ម ។

ខ) បញ្ជីវត្ថុតាង ដែលភាគីទាំងឡាយមានបំណងប្រគល់ឲ្យសម្រាប់រឿងក្តីនោះ ដោយមានពិពណ៌នាត្រួសៗអំពីលក្ខណៈ និងខ្លឹមសារនៃវត្ថុតាងទាំងនោះ ។

គ) ការបង្ហាញអំពីអង្គច្បាប់ ដែលភាគីទាំងឡាយមានបំណងលើកឡើងនៅក្នុងសវនាការបឋមប្រសិនបើមាន ។

ឃ) បញ្ជីឯកសារថ្មី ដោយមានភ្ជាប់សេចក្តីសង្ខេបពីខ្លឹមសារនៃឯកសារទាំងនោះ ដែលភាគីមានបំណងចង់ដាក់ចំពោះមុខអង្គជំនុំជម្រះ និងបញ្ជីឯកសារដែលមានស្រាប់នៅក្នុងសំណុំរឿង ដែលបានកំណត់អត្តសញ្ញាណសមស្រប ។ និង

ង) បញ្ជីនៃអង្គហេតុដែលមិនមានការជំទាស់ ដោយយោងទៅភស្តុតាងដែលពាក់ព័ន្ធផង ។

១២ សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹក នៅសំណុំរឿង០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣, ឯកសារ E299, កថាខណ្ឌ២២ ។

១៣ ដដែលដូចខាងលើ ។

១៤ ដដែលដូចខាងលើ ។ កថាខណ្ឌ៣ ។

១៥ ដដែលដូចខាងលើ ។ កថាខណ្ឌ១៧ ។

១៦ ដដែលដូចខាងលើ ។ កថាខណ្ឌ១៨ ។

១៧ ដដែលដូចខាងលើ ។ កថាខណ្ឌ១៩ ។

១៨ ដដែលដូចខាងលើ ។ កថាខណ្ឌ២៣ ។

១៩ ដដែលដូចខាងលើ ។ កថាខណ្ឌ៤៣ ។

២០ ដដែលដូចខាងលើ ។ កថាខណ្ឌ៤៤ ។

២១ សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង, ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩, កថាខណ្ឌ១៤, ឯកសារ E43/4 ។

២២ ដដែលដូចខាងលើ ។ កថាខណ្ឌ១៥ ។

២៣ សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹក នៅសំណុំរឿង០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣, ឯកសារ E299, កថាខណ្ឌ២៩ ។

២៤ ដដែលដូចខាងលើ ។



នួន ជា កំពុងជល់កែវក្នុងពិធីអាហារពេលល្ងាចមួយក្នុងរបបកម្ពុជាប្រធិតេយ្យ



ជាមួយគណៈប្រតិភូបរទេស ។ (បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

# វិធានការការពារ ជនរងគ្រោះ និង សាក្សី នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ចាន ប្រាថ្នា

## ១) *គោលបំណងនៃការផ្តល់វិធានការការពារ*

*អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតឡើងដើម្បីវិនិច្ឆ័យទោសមេដឹកនាំ ជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលកើតឡើងនៅប្រទេសកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ឧក្រិដ្ឋកម្មជាច្រើនបានកើតឡើងស្ទើរគ្រប់ទីកន្លែងនៃប្រទេសកម្ពុជា ។ នៅក្នុងដំណើរការជំនុំជម្រះក្តីទៅលើឧក្រិដ្ឋកម្មដែលមានលក្ខណៈធ្ងន់ធ្ងរ និងធំធេងបែបនេះ បញ្ហាសន្តិសុខ និងសុវត្ថិភាព ទទួលបានការយកចិត្តទុកដាក់ជាខ្លាំង ។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[១] វិធានផ្ទៃក្នុង[២] និងបទបញ្ញត្តិផ្សេងៗទៀត[៣] បានតម្រូវឲ្យអង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើការធានា និងការពារសន្តិសុខជូនជនរងគ្រោះដែលជាអ្នកប្តឹង ឬដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីឲ្យបានត្រឹមត្រូវ ។ បន្ថែមពីលើការផ្តល់សន្តិសុខផ្នែកផ្លូវកាយ វិធានការការពារនៅអង្គជំនុំជម្រះវិសាមញ្ញ (តាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញ) បានធានាផ្តល់ការការពារសន្តិសុខផ្នែកផ្លូវចិត្ត (ភាពគ្មានតឹងផ្លូវចិត្ត និងអារម្មណ៍) ដល់អ្នកដែលមានការព្រួយបារម្ភថានឹងអាចមានអ្វីមួយកើតឡើងដោយសារការផ្តល់សក្ខីកម្មរបស់ខ្លួន ។ បុព្វហេតុនៃការផ្តល់ការការពារផ្នែកផ្លូវចិត្ត ដោយសារ "សាក្សីជាច្រើនមានអារម្មណ៍ភ័យខ្លាច និងច្របូកច្របល់នៅមុនពេលចូលខ្លួនផ្តល់សក្ខីកម្ម ហើយត្រូវការជំនួយ ការធានា និងព័ត៌មាន អំពីអ្វីដែលនឹងអាចកើតឡើង" ។[៤] ដូច្នេះ គោលបំណងនៃការផ្តល់វិធានការការពារជូនដល់ជនរងគ្រោះ និងសាក្សី គឺដើម្បីធានាថា អ្នកទាំងនោះមានសន្តិសុខ សុវត្ថិភាព និងមានភាពសុខស្រួលក្នុងការប្តឹងបរិហារ ឬប្តឹងទាមទារសំណង និងផ្តល់សក្ខីកម្មអំពីឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។*

## ២) *ប្រភេទ និងវិសាលភាពនៃវិធានការការពារ*

*វិធានការការពារនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានច្រើនយ៉ាង ។ វិធានការទាំងនេះ ត្រូវបានប្រើដើម្បីលាក់បាំងអត្តសញ្ញាណរបស់បុគ្គលដែលទទួលបានការការពារ ។ នៅពេលសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះសម្រេចផ្តល់វិធានការការពារជូនដល់អ្នកប្តឹង ដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីណាម្នាក់ វិធានការមួយចំនួនដូចខាងក្រោមអាចនឹងត្រូវបានប្រើប្រាស់ដើម្បីការពារអត្តសញ្ញាណរបស់បុគ្គលនោះដោយ[៥] ៖*

*ក-កំណត់យកអាស័យដ្ឋានរបស់មេធាវីរបស់បុគ្គលនោះ ឬរបស់សមាគមជនរងគ្រោះរបស់បុគ្គលនោះ ឬរបស់អង្គជំនុំជម្រះវិសាមញ្ញ ជាអាស័យដ្ឋានទំនាក់ទំនងរបស់បុគ្គលដែលទទួលបានការការពារនោះ ។ គួរកត់សម្គាល់ថា ករណីនេះ ត្រូវបានអនុវត្តនៅពេលដែលការធ្វើទំនាក់ទំនងដោយផ្ទាល់ ជាមួយបុគ្គលនោះអាចធ្វើឲ្យគាត់មានគ្រោះថ្នាក់ដល់ជីវិត ឬដល់សុខមាលភាព (វិធាន២៩(២)) ។*

*ខ-ប្រើរហស្សនាមនៅពេលនិយាយសំដៅទៅរកជនដែលត្រូវការពារនោះ ។*

*គ-អនុញ្ញាតឲ្យធ្វើកំណត់ហេតុសួរយកចម្លើយរបស់ជននោះដោយមិនចាំបាច់សរសេរអត្តសញ្ញាណរបស់ជននោះនៅក្នុងសំណុំរឿង ។*

*ឃ-នៅពេលជនត្រូវចោទ ឬជនសង្ស័យស្នើឲ្យមានការឆ្លើយតទល់គ្នាជាមួយជននោះ គេអាចប្រើប្រាស់បច្ចេកទេសដែលអនុញ្ញាតឲ្យមានការចូលរួមពីចម្ងាយ ឬបំប្លែងសំឡេងដើម ឬបិទបាំងកិនភាគរបស់ជននោះ ។*

*ង-ជាករណីលើកលែងចំពោះគោលការណ៍សវនាការជាសាធារណៈ អង្គជំនុំជម្រះអាចរៀបចំផ្នែកដំណើរការនីតិវិធីណាមួយជាសម្ងាត់ ឬអនុញ្ញាតឲ្យបង្ហាញភ័ស្តុតាងតាមរយៈប្រព័ន្ធ*

អេឡិចត្រូនិច ឬប្រើប្រាស់មធ្យោបាយពិសេសៗដទៃទៀត ។

វិធានការសម្រាប់ការពារអ្នកប្ដឹង ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី ត្រូវបានពង្រីកបន្ថែមទៀត តាមរយៈសេចក្ដីណែនាំស្ដីពីការអនុវត្តវិធានការការពារ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មាត្រា៣ (ស្ដីអំពីវិសាលភាពនៃវិធានការការពារ) នៃសេចក្ដីណែនាំនេះចែងថា[៦] ៖

**៣.១)** បន្ថែមពីលើវិធានការការពារដែលមានចែងនៅក្នុងវិធាន ២៩(៤) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចចេញវិធានការដូចខាងក្រោម ៖

ក-បង្គាប់ឲ្យធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ ឬកំណត់ហេតុនៃផ្នែកពិសេសណាមួយនៃនីតិវិធី ដោយរក្សាទុកតាមរបៀប"បិទស្លាកបោះត្រា" ។

ខ-ហាមឃាត់សាធារណជនចូលពិនិត្យមើលឯកសារពិសេសណាមួយក្នុងសំណុំរឿង ឬទទួលបាននូវសំណុំឯកសារ ដែលបង្ហាញពីអត្តសញ្ញាណនៃបុគ្គលដែលត្រូវការពារ ។

គ-ចេញវិធានការដើម្បីការពារជារូបវន្តដល់បុគ្គលដែលត្រូវការពារ ជាពិសេស ការផ្ដល់ជាកន្លែងស្នាក់នៅដែលមានសុវត្ថិភាព នៅក្នុង ឬក្រៅប្រទេសកម្ពុជា ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងស្ដីអំពីការផ្លាស់ប្ដូរលំនៅដ្ឋាន ។ គួរបញ្ជាក់ថា បទបញ្ញត្តិនេះមានលក្ខណៈស្រដៀងគ្នាទៅនឹងវិធាន ២៩(៧) នៃវិធានផ្ទៃក្នុង ។ វិធាននេះចែងថា "ក្នុងករណីចាំបាច់ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចបង្គាប់ឲ្យមានការធានាសមស្របតាមផ្លូវតុលាការ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ និង/ឬ ការការពារជារូបវន្តដល់ជនរងគ្រោះ ឬសាក្សី ដោយឲ្យស្ថិតនៅក្នុងលំនៅដ្ឋានសុវត្ថិភាព ក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅឯបរទេស" ។

ឃ-បន្ថែមពីលើវិធាន ២៩(៤)(ខ) ដកចេញនូវរាល់កំណត់ហេតុទាំងឡាយពីសំណុំរឿងដែលឲ្យគេស្គាល់នូវអត្តសញ្ញាណរបស់បុគ្គលដែលត្រូវការពារ ឬព័ត៌មានផ្សេងទៀតដែលអាចបង្ហាញអំពីអត្តសញ្ញាណ ឬទីកន្លែង ។

**៣.២)** ដើម្បីអនុវត្តវិធានការការពារ ជាពិសេសបិតក្នុងអំឡុងពេលនៃនីតិវិធី តទល់គ្នារបស់ភាគី និងសវនាការ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចប្រើមធ្យោបាយអេឡិចត្រូនិចដូចខាងក្រោម ៖



កម្មាភិបាលនារីខ្មែរក្រហមកំពុងត្បាញក្រណាត់នៅរោងចក្រតម្បាញក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក-ការបំប្លែងសំឡេង ឬទម្រង់រូបកាយរបស់បុគ្គលដែលត្រូវការពារ ។

ខ-ការប្រើប្រព័ន្ធរូបភាព និងសំឡេង ជាពិសេស Video-conferencing or closed circuit television ។

គ-ការប្រើតែមធ្យោបាយសំឡេងក្នុងការទំនាក់ទំនង ។

ឃ-មធ្យោបាយអេឡិចត្រូនិចដទៃទៀត ដែលអាចការពារបុគ្គលដែលត្រូវការពារនោះ ។

***២,៣)*** សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តាមករណីសមស្រប ត្រូវធានាថា នៅពេលផ្តល់ធាតុផ្សំនៃភ័ស្តុតាងណាមួយ បុគ្គលដែលត្រូវការពារត្រូវបានផ្តល់ព័ត៌មានថា សក្ខីកម្មរបស់ខ្លួន ឬអត្តសញ្ញាណរបស់បុគ្គលនោះ អាចនឹងត្រូវបញ្ចេញឲ្យដឹងនៅក្នុងដំណាក់កាលនៃសំណុំរឿងផ្សេង [...] ។

ក្រៅពីវិធានការទាំងអស់ដូចបានរៀបរាប់ខាងលើនេះ វិធានការមួយចំនួនទៀតសម្រាប់ការពារសាក្សី អាចរកបាននៅក្នុងវិធាន២៨ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ តាមរយៈវិធាននេះ សាក្សីអាចទទួលបានការធានាថា សក្ខីកម្មរបស់ខ្លួននឹងត្រូវបានរក្សាជាការសម្ងាត់ ហើយនឹងមិនត្រូវបានប្រើសម្រាប់ចោទប្រកាន់មកលើខ្លួនឡើយ ។ ករណីនេះនឹងត្រូវអនុវត្តនៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តម្រូវឲ្យសាក្សីនោះឆ្លើយសំណួរណាមួយដែលអាចដាក់បន្ទុកលើខ្លួនឯង ។

ជាគោលការណ៍ នៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពោលគឺចាប់តាំងពីដំណាក់កាលស៊ើបអង្កេតបឋម ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា រហូតដល់ដំណាក់កាលជំនុំជម្រះសេចក្តី សាក្សីមានសិទ្ធិមិនឆ្លើយតបសំណួរ ឬធ្វើអំណះអំណាងណាមួយដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ។ សិទ្ធិនេះហៅថា "សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង" ។ ដូច្នេះ នៅពេលសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះតម្រូវឲ្យសាក្សីឆ្លើយសំណួរមួយ ឬច្រើន សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវធានាថា ភ័ស្តុតាងដែលឆ្លើយតបនឹងសំណួរនោះ ៖

ក-ត្រូវរក្សាជាការសម្ងាត់ និងមិនត្រូវបើកចំហរដល់សាធារណជន និង/ឬ

ខ-មិនត្រូវបានប្រើប្រាស់ដោយផ្ទាល់ ឬដោយប្រយោលប្រឆាំងនឹងសាក្សីនោះនៅក្នុងការចោទប្រកាន់បន្តបន្ទាប់ទៀតដែលធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញឡើយ ។[7]

គួររំពឹកថា ការធានាដូចបានបញ្ជាក់នៅក្នុងចំណុច "ខ" ខាងលើនេះ គឺនៅមានហានិភ័យនូវឡើយសម្រាប់សាក្សី ។ នៅក្នុងចំណុចនេះ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះផ្តល់ការធានាជូនសាក្សីឲ្យរួចផុតពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប៉ុន្តែពុំបានផ្តល់ការធានាឲ្យរួចផុតពីយុត្តាធិការរបស់តុលាការជាតិឡើយ ។ និយាយឲ្យខ្លីសាក្សីនោះពុំទទួលបានការធានាឲ្យរួចផុតពីការចោទប្រកាន់ ដែលអាចនឹងធ្វើឡើងដោយតុលាការជាតិឡើយ ។ ករណីស្រដៀងគ្នានេះ ត្រូវបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញ ។[8]

### ៣) នីតិវិធី និង លក្ខខណ្ឌក្នុងការទទួលបានវិធានការការពារ

វិធាន២៩(៣) នៃវិធានផ្ទៃក្នុងចែងថា "តាមការផ្តួចផ្តើមគំនិតរបស់ខ្លួន ឬតាមពាក្យសុំ និងក្រោយពេលពិគ្រោះយោបល់ជាមួយអង្គភាពគាំពារជនរងគ្រោះ ឬអង្គភាពគាំពារសាក្សី និងអ្នកជំនាញ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចចាត់វិធានការសមស្របដើម្បីការពារ អ្នកប្តឹង ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលមកបង្ហាញខ្លួន ប្រសិនបើការបង្ហាញខ្លួននោះអាចធ្វើឲ្យអាយុជីវិត សុខមាលភាព ឬក្រុមគ្រួសារ ឬញាតិជិតស្និទ្ធរបស់ពួកគេត្រូវស្ថិតក្នុងសភាពគ្រោះថ្នាក់ធ្ងន់ធ្ងរ ។ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចចេញដីកាបែបនេះ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ក្នុងករណីដែលមានការបង្ហាញអំពីហានិភ័យបែបនេះនៅក្នុងសំណុំរឿង [...]" ។ យោងតាមវិធាននេះ ការផ្តល់វិធានការការពារជូន អ្នកប្តឹង ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីជាសិទ្ធិអំណាចផ្តាច់មុខរបស់សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ ។[9] ដូច្នេះ ភាគីណាមួយ (ឬមេធាវីរបស់ភាគីនោះ) ដែលមានបំណងស្នើសុំវិធានការការ ត្រូវធ្វើសំណើសុំជាលាយលក្ខណ៍អក្សរដាក់ជូន (តាមរយៈក្រឡាបញ្ជី ឬមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង) សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ។ សំណើសុំវិធានការការពារ ជនរងគ្រោះ និងសាក្សី ត្រូវបានអនុញ្ញាតឲ្យបន្តដាក់ក្នុងរយៈពេល១៥ថ្ងៃបន្ថែមទៀត បន្ទាប់ពីដីកា

បញ្ជូនរឿងទៅជំនុំជម្រះចូលជាស្ថាពរ ។ ផុតពីរយៈពេលនេះការស្នើសុំវិធានការការពារនឹងមិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែមាន“ករណីពិសេស”ប៉ុណ្ណោះ ។

លក្ខខណ្ឌក្នុងការទទួលបានវិធានការការពារនៅអង្គជំនុំជម្រះវិសាមញ្ញត្រូវបានកម្រិតយ៉ាងតឹងរ៉ឹង ។ អ្នកដាក់ពាក្យសុំវិធានការការពារត្រូវបានតម្រូវឲ្យបង្ហាញអំពីការភ័យខ្លាចដាក់ស្តែងរបស់ខ្លួន (ឬសាច់ញាតិរបស់ខ្លួន) ព្រមទាំងអត្ថិភាពនៃភ័ស្តុតាងដែលបង្កើតឲ្យមានការភ័យខ្លាចនោះ ។ បានន័យការយល់ឃើញអំពីការគ្រោះថ្នាក់បែបអត្តនោម័តិរបស់អ្នកដាក់ពាក្យសុំពុំទាន់គ្រប់គ្រាន់សម្រាប់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះពិចារណាក្នុងការផ្តល់វិធានការពារឡើយ ។ បុគ្គលនោះចាំបាច់ត្រូវបង្ហាញបន្ថែមទៀតអំពីហានិភ័យពិតប្រាកដ ដែលអាចបង្កឲ្យមានព្យសនកម្មមកលើរូបខ្លួនផ្ទាល់ ឬក្រុមគ្រួសារ ។ សហចៅក្រមស៊ើបអង្កេតធ្លាប់បានបញ្ជាក់ថា “ពាក្យសុំនោះ [ពាក្យសុំវិធានការការពារ] ត្រូវបញ្ជាក់ឲ្យបានច្បាស់អំពីអត្តសញ្ញាណរបស់ភាគី និងបុគ្គលទាំងអស់ដែលត្រូវទទួលវិធានការការពារ និងត្រូវបញ្ជាក់ថាប្រសិនបើមិនមានវិធានការពារទេនោះ អាយុជីវិត និងសុខមាលភាពរបស់បុគ្គលទាំងនេះ ឬក្រុមគ្រួសាររបស់ពួកគេ នឹងស្ថិតក្នុងគ្រោះថ្នាក់” ។ អង្គជំនុំជម្រះសាលាដំបូងបានយោងទាំងស្រុងចំពោះការលើកឡើងនេះ និងបញ្ជាក់បន្ថែមថា “[...] វិធានការការពារត្រូវបានផ្តល់ឲ្យតាមករណីនីមួយៗ នៅពេលដែលសំណើនោះមានព័ត៌មានគ្រប់គ្រាន់ស្តីអំពីអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំ និងការបញ្ជាក់ដ៏លម្អិតអំពីគ្រោះថ្នាក់ ឬព្យសនកម្ម ដែលអ្នកដាក់ពាក្យសុំ ឬក្រុមគ្រួសាររបស់ពួកគេនឹងប្រឈម ។ បន្ថែមពីនេះទៀត ពាក្យសុំនោះចាំបាច់ត្រូវឲ្យមានការបញ្ជាក់ពីការភ័យខ្លាចដ៏ពិតប្រាកដរបស់អ្នកដាក់ពាក្យសុំ និងក្រុមគ្រួសាររបស់ពួកគេ ព្រមទាំងអត្ថិភាពនៃមូលហេតុដ៏ច្បាស់លាស់ចំពោះ ការភ័យខ្លាចនេះ” ។[១០]

គួរកត់សម្គាល់ថា ការតម្រូវឲ្យបំពេញលក្ខខណ្ឌទាំងនេះ ជនរងគ្រោះដែលជា អ្នកប្តឹង ឬដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីទំនងជាមានការលំបាកក្នុងការបង្ហាញភ័ស្តុតាងដើម្បីទទួលបានវិធានការការពារ ។ ពិតប្រាកដណាស់ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី អាចមានភាពងាយស្រួលក្នុងការបង្ហាញភ័ស្តុតាងទាំងនេះដោយផ្តល់ព័ត៌មានលម្អិតអំពីគ្រោះថ្នាក់ ឬព្យសនកម្មដែលនឹងត្រូវប្រឈម ប្រសិនបើរូបគាត់ (ឬក្រុមគ្រួសាររបស់ខ្លួន) ត្រូវបានគំរាមកំហែង (តាមរយៈពាក្យសម្តី ឬព្រឹត្តិការណ៍ជាក់លាក់ណាមួយ) មុនពេលចូលខ្លួនទៅផ្តល់សក្ខីកម្មនៅតុលាការ ។ ក្រៅពីលក្ខខណ្ឌនេះ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី នឹងមានការលំបាកក្នុងការបង្ហាញអំពីហានិភ័យដែលខ្លួនត្រូវប្រឈម ។

## ៤) ការអនុវត្ត និង បញ្ហាប្រឈម

នៅក្នុងដំណើរការជំនុំជម្រះសេចក្តីទៅលើសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងអ្នកជំនាញ សរុបទាំងអស់៩២រូប ។ ក្នុងចំណោមអ្នកទាំងនេះ ពុំមានបុគ្គលណាម្នាក់ទទួលបានវិធានការការពារឡើយ នៅក្នុងអំឡុងពេលសវនាការស្តាប់សក្ខីកម្ម ។ នៅពេលចូលដល់បន្ទប់សវនាការភ្លាម អ្នកទាំងនោះត្រូវអង្គជំនុំជម្រះសួរលម្អិតអំពីអត្តសញ្ញាណរបស់ខ្លួន ទីលំនៅបច្ចុប្បន្ន និងឈ្មោះឪពុកម្តាយ ប្តី ឬប្រពន្ធជាដើម ដែលអាចធ្វើឲ្យសាធារណជនស្គាល់យ៉ាងច្បាស់ ។ នៅពេលផ្តល់សក្ខីកម្ម សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនត្រូវបានភាគី ឬអង្គជំនុំជម្រះសួរដេញដោលយ៉ាងលម្អិតអំពីអង្គហេតុឧក្រិដ្ឋកម្មណាមួយ ឈ្មោះជនដៃដល់ និងខ្សែសង្វាក់នៃការបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ ។ ការសួរដេញដោលត្រូវបានធ្វើជាសាធារណៈ ហើយមានពេលខ្លះមានការផ្សាយបន្តផ្ទាល់តាមទូរទស្សន៍ ដែលអាចមើលបាននៅទូទាំងប្រទេស ។

ករណីទាំងនេះ តើអាចមានការភ័យខ្លាចយ៉ាងណាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ទាំងនៅក្នុងអំឡុង និងក្រោយពេលសវនាការនៅពេលដែលសក្ខីកម្មរបស់ខ្លួនត្រូវបានគេស្តាប់ឮជាសាធារណៈ ។ ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន បានសម្រេចឈប់ផ្តល់សក្ខីកម្មនៅពាក់កណ្តាលទីនៅពេលសហព្រះរាជអាជ្ញាសួរដេញដោលអំពីវគ្គរៀនសូត្រនយោបាយដែល ស សារិន បានចូលរួមក្រោមបទទុទ្ទេសនាមរបស់ នួន ជា និង ខៀវ សំផន ។ ស សារិន បានផ្តល់ហេតុផលថា គាត់មានការភ័យខ្លាចអំពីបញ្ហាអសន្តិសុខ ដែលនឹងអាចគំរាមកំហែងដល់ក្រុមគ្រួសារ ឬអាយុ

ជីវិតរបស់គាត់ ដែលជាលទ្ធផលនៃការផ្តល់សក្ខីកម្មរបស់ខ្លួន ។ ស សារិន អះអាងទៀតថា ផាន់ ង៉ោ ត្រូវបានគេសម្លាប់ ដោយសារគាត់និយាយអំពីនយោបាយរបស់ខ្មែរក្រហម ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ស្នើសុំការអន្តរាគមន៍ពីអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដោយចាត់តាំងកងកម្លាំងប្រដាប់អាវុធចំនួន ៤នាក់ ដើម្បីការពាររហូតដល់គាត់អស់ជីវិត (ដែលរាល់ការចំណាយផ្សេងៗ ដូចជា ប្រាក់បៀវត្ស ថ្លៃបាយទឹក ។ល ។ សម្រាប់អ្នកការពារទាំងនោះជាបន្ទុករបស់រដ្ឋ) ក្នុងករណីដែលអង្គជំនុំជម្រះ នៅតែចង់ឲ្យគាត់ផ្តល់សក្ខីកម្មអំពីអ្វីដែល នួន ជា និង ខៀវ សំផន បានអប់រំនៅក្នុងវគ្គរៀនសូត្រនយោបាយនោះ ។ ជាការឆ្លើយតប អង្គជំនុំជម្រះបញ្ជាក់ថា "...សំណើរបស់លោកដែលបានសុំឲ្យអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាផ្តល់កិច្ចការពារសន្តិសុខសម្រាប់រូបលោកចាប់ពីពេលនេះ រហូតដល់អស់មួយជីវិតនោះ គឺមិនមានហេតុផលសមស្របទេ ។ អង្គជំនុំជម្រះសូមជម្រាបផងដែរថា អង្គជំនុំជម្រះគ្មានយុត្តាធិការសម្រេចតាមសំណើរបស់លោកបែបនេះទេ ។ អង្គជំនុំជម្រះក៏មិនសម្រេចផ្តល់នូវវិធានការផ្សេងៗទៀតជូនលោកដែរ ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចបញ្ចប់ការស្តាប់សក្ខីកម្មរបស់លោកត្រឹមនេះ [...]" ។[១១] នៅសវនាការថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបាន បញ្ជាក់បន្ថែមថា វិធានការដែល ស សារិន ស្នើសុំនោះ "នៅក្រៅសមត្ថកិច្ចនៃអង្គជំនុំជម្រះសាលាដំបូងដែលអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក នេះ មិនអាចអនុវត្តបានទេ ។ [...] អង្គជំនុំជម្រះមិនមានយុត្តាធិការផ្តល់នូវកិច្ចការពារដូចដែលលោក [ស សារិន] បានស្នើសុំ ។ ដូចជាការដែលលោកស្នើសុំឲ្យចាត់វិធានការដាក់កងកម្លាំងការពារសុវត្ថិភាពលោករហូតដល់អស់មួយជីវិត ឬក៏សុំការផ្លាស់ទីលំនៅទៅនៅក្រៅប្រទេស ដើម្បីរស់នៅក្រៅប្រទេសជាដើមនោះ គឺវាមិនមានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះទេ" ។[១២] តាមរយៈសេចក្តីសម្រេចនេះ អាចទាញបានថា ទោះបីវិធាន ២៩(៧) នៃវិធានផ្ទៃក្នុងចែងថា "ក្នុងករណីចាំបាច់ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាចបង្គាប់ឲ្យមានការធានា សមស្របតាមផ្លូវតុលាការ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ និង/ឬការពារជារូបវន្តដល់ជនរងគ្រោះ ឬសាក្សី ដោយឲ្យស្ថិតនៅក្នុងលំនៅដ្ឋានសុវត្ថិភាពក្នុងព្រះរាជាណាចក្រកម្ពុជា ឬនៅក្រៅប្រទេស" ក៏ដោយប៉ុន្តែសម្រាប់ការអនុវត្តនៅតែជួបបញ្ហាប្រឈម ។

គួរបញ្ជាក់ថា សហព្រះរាជអាជ្ញាបានប៉ុនប៉ងម្តងហើយម្តងទៀតក្នុងការស្នើអង្គជំនុំជម្រះសាលាដំបូងកោះហៅ ស សារិន (ដោយបង្ខំ) ឲ្យមកផ្តល់សក្ខីកម្មទាក់ទងនឹងបទខុទ្ទេសនាមរបស់ នួន ជា និង ខៀវ សំផន ដែលបានថ្លែងនៅក្នុងកិច្ចប្រជុំរៀនសូត្រនយោបាយនោះ ។ ប៉ុន្តែសំណើនេះ ត្រូវបានបដិសេធចោល



រូបថតអនុស្សាវរីយ៍របស់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនិ
ការវិវត្តការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

ដោយអង្គជំនុំជម្រះផ្តល់ហេតុផលថា ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចត្រូវបានបង្ខំឲ្យផ្តល់សក្ខីកម្មឡើយ ។[១៣]

១ មាត្រា៣៣ថ្មី ចែងថា "អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និង សាក្សី [..]" ។

៧ វិធាន ២៩ ចែងថា "អង្គជំនុំជម្រះវិសាមញ្ញត្រូវធានានូវអំពីកិច្ចការពារដល់អ្នកប្តឹង ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី[..]" ។

៣ បទបញ្ញត្តិទាំងនោះរួមមាន កិច្ចព្រមព្រៀងបំពេញបន្ថែមស្តីអំពីសន្តិសុខ និងសុវត្ថិភាព និងសេចក្តីណែនាំអនុវត្តអំពីវិធានការការពារ ។

៤ "វិធានការការពារនៅក្នុងដំណើរការនីតិវិធីនៅ អ.វ.ត.ក" ចុះផ្សាយថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៣ ដោយលោកស្រី វេនឌី ឡុបវីន អ្នកសម្របសម្រួលនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/blog/2013/05/03/26296 (ចូលមើលថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៣) ។



និស្សិតសកលវិទ្យាល័យជាតិគ្រប់គ្រង បន្ទាប់ការធ្វើបទបង្ហាញអំពីដំណើរ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

៥ វិធាន២៩ កថាខណ្ឌ ៤ ។

៦ "សេចក្តីណែនាំអនុវត្តអំពីវិធានការការពារ អ.វ.ត.ក/០៣/២០០៧/វ០១" វិសោធនកម្មថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៨ ។ អាចរកបាន ៖ http://www.eccc.gov.kh/sites/default/files/legal-documents/PD-Protective-Measures-Eng_0.pdf (ចូលមើលថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៣) ។

៧ វិធាន ២៨ កថាខណ្ឌ ៣ ។

៨ សូមមើល"ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំអនុញ្ញាតក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដល់សាក្សីនានា" ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/document/court/20647 (ចូលមើលថ្ងៃទី៤ ខែធ្នូ ឆ្នាំ ២០១៣) ។

៩ សូមមើលបន្ថែមនៅត្រង់មាត្រា១ នៃសេចក្តីណែនាំអនុវត្តអំពីវិធានការការពារ ។

១០ សេចក្តីសម្រេចអំពីវិធានការការពារសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៩ ឯកសារលេខ E71 កថាខណ្ឌ៧ ។ អាចរកបានក្នុងគេហទំព័រ ៖ http://www.eccc.gov.kh/document/court/14576 (ចូលមើល ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៣) ។ សូមមើលបន្ថែមនៅអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី"សេចក្តីសម្រេចលើសំណើសុំវិធានការការពារទាំងអស់នៅក្នុងសំណុំរឿង០០២/០១ និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស សារិន សាជាថ្មី និងបន្ទាប់ឲ្យមានការវាយតម្លៃជាផ្លូវការមួយពីតម្រូវការចាំបាច់សម្រាប់វិធានការការពារ" ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣ ឯកសារលេខ E293 កថាខណ្ឌ៧ ។ អាចរកបាន ៖ http://www.eccc.gov.kh/document/court/26741 (ចូលមើលថ្ងៃទី៤ ខែធ្នូឆ្នាំ២០១៣) ។

១១ ប្រតិចារិកសវនាការថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ ត្រង់ទំព័រ ៥០-៥១ ឯកសារលេខ E1/185.1 ។ អាចរកបាន ៖ http://www.eccc.gov.kh/document/court/26348 (ចូលមើល ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៣) ។

១២ ប្រតិចារិកសវនាការថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ត្រង់ទំព័រ ៣១-៣២ ឯកសារលេខ E1/227.1 ។ អាចរកបាន ៖ http://www.eccc.gov.kh/document/court/27065 (ចូលមើល ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៣) ។

១៣ ឯកសារលេខ E293 កថាខណ្ឌ១៣

# សិទ្ធិទទួលបានមេធាវីការពារក្ដី និងភាពចាំបាច់ក្នុងការអនុវត្តសិទ្ធិនេះ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ដោយ ចាន់ ប្រាថ្នា**

## សេចក្ដីផ្ដើម

នៅក្នុងកិច្ចដំណើរការរឿងក្ដីព្រហ្មទណ្ឌ វត្តមានរបស់មេធាវីការពារក្ដី គឺមានសារៈសំខាន់ និងចាំបាច់បំផុតសម្រាប់ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ[១] ដើម្បីរួមចំណែកក្នុងការធានាថា កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលទាំងនោះ បានប្រព្រឹត្តទៅប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ។ មេធាវីមានតួនាទីយ៉ាងសំខាន់ក្នុងការណែនាំកូនក្ដីរបស់ខ្លួនអំពីសិទ្ធិ និងករណីកិច្ចផ្សេងៗដែលអាចអនុវត្តបានក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី ។ ជាងនេះទៅទៀត មេធាវីការពារក្ដីអាចអនុវត្តតួនាទីរបស់ខ្លួន យ៉ាងសកម្មនៅគ្រប់កិច្ចដំណើរការនីតិវិធីរបស់តុលាការ ដើម្បីការពារផលប្រយោជន៍កូនក្ដីរបស់ខ្លួន ។

មូលដ្ឋានច្បាប់ជាច្រើន (ដូចបានលើកឡើងទាំងស្រុងនៅក្នុងចំណុចទី១ ខាងក្រោម) បានធានាដល់ជនគ្រប់រូបក្នុងការទទួលបានមេធាវីការពារក្ដី និងការជូនដំណឹងអំពីសិទ្ធិនេះ នៅគ្រប់កិច្ចដំណើរការនីតិវិធីនៃរឿងក្ដីព្រហ្មទណ្ឌ (បញ្ជាក់លម្អិតក្នុងចំណុច១.១) និងទទួលបានដោយឥតគិតថ្លៃ ប្រសិនបើខ្លួនគ្មានលទ្ធភាពបង់កម្រៃសេវាមេធាវី (លក្ខណៈវិនិច្ឆ័យក្នុងការកំណត់ជនក្រីក្រ គឺត្រូវបានរៀបរាប់នៅក្នុងចំណុច១.២) ។ សិទ្ធិនេះត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ នៅក្នុងមជ្ឈដ្ឋានច្បាប់ជាតិ (ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា...) និងច្បាប់អន្តរជាតិ (កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ) ហើយត្រូវបានអនុវត្តនៅតុលាការអន្តរជាតិមួយចំនួនដូចជា ៖ តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា (ICTR) តុលាការពិសេស សម្រាប់ប្រទេសសេរ៉ាឡេអូន (SCSL) រួមទាំងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។[២]

ទោះបីជាយ៉ាងណាក៏ដោយ ការសម្រេចអនុវត្ត ឬបោះបង់ចោលសិទ្ធិទទួលបានមេធាវីការពារក្ដី គឺជាសេរីភាពរបស់ជនសង្ស័យ និងជនត្រូវចោទ ។[៣] ជនទាំងនេះអាចសម្រេចបោះបង់សិទ្ធិមានមេធាវី ការពារក្ដី ហើយការពារខ្លួននៅចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបអង្កេត ដោយពុំចាំបាច់មានជំនួយមេធាវី (លើកលែងតែជនត្រូវចោទ គឺជាអនីតិជនដែលច្បាប់បានតម្រូវឲ្យត្រូវតែមានមេធាវីអម) ។ ក្នុងករណីនេះ នៅគ្រប់ពេលវេលានៃការសួរយកចម្លើយជនសង្ស័យ ឬជនត្រូវចោទ គឺមិនត្រូវបានរាំងស្ទះដោយសារតែអវត្តមានមេធាវីការពារក្ដីឡើយ ។ ប៉ុន្តែប្រសិនបើជនសង្ស័យ ឬជនត្រូវចោទ សម្រេចទទួលយកជំនួយពីមេធាវីការពារក្ដី នោះការសួរយកចម្លើយជនទាំងនេះ គឺដាច់ខាតត្រូវធ្វើឡើង ដោយមានវត្តមានរបស់មេធាវីការពារក្ដី លើកលែងតែមានការបញ្ជាក់យ៉ាងច្បាស់ពីជនសង្ស័យ ឬជនត្រូវចោទថា ខ្លួនអាចផ្ដល់ចម្លើយដោយពុំចាំបាច់មានវត្តមានរបស់មេធាវីការពារក្ដី ។

### ១) មូលដ្ឋានច្បាប់ដែលធានាដល់សិទ្ធិទទួលបានមេធាវីការពារក្ដី

សិទ្ធិទទួលបានមេធាវីការពារក្ដីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺត្រូវបានកំណត់នៅក្នុងបទបញ្ញត្តិជាច្រើន ដែលមានអានុភាពយកមកអនុវត្តនៅតុលាការមួយនេះ ។ បទបញ្ញត្តិទាំងនោះ រួមមាន ៖

ទី១) កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រង់មាត្រា១៤(៣)(ឃ) ។ មាត្រានេះចែងថា ជនគ្រប់រូបមានសិទ្ធិ« ទទួលការជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួន ដោយខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួនក្នុងករណី ដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃនៅក្នុងករណីជន

ជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ដើម្បីចំណាយទៅលើជំនួយការច្បាប់នេះ» ។[៤]

ទី២) ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៧ ។ ក្នុងក្រមនេះមានមាត្រាជាច្រើនចែងពាក់ព័ន្ធ នឹងសិទ្ធិទទួលបានមេធាវីការពារក្តី ។[៥] មាត្រាទាំងនោះរួមមាន ៖

- មាត្រា៩៨ ៖ ស្តីពីជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួនបានចែងថា «ក្នុងរយៈពេល២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្តើមនៃការឃាត់ខ្លួនមក បុគ្គលដែលត្រូវបានឃាត់ខ្លួនអាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនបានជ្រើសរើស...» ។
- មាត្រា១៤៣ ៖ ស្តីពីការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យត្រង់កថាខណ្ឌទី៣ «ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទឲ្យបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការជ្រើសរើសមេធាវី ឬក្នុងការសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួន ដោយអនុវត្តច្បាប់ស្តីពីលក្ខន្តិកៈមេធាវី» ។ កថាខណ្ឌទី៤ ចែងបន្ថែម«ជនជាប់ចោទជាអនីតិជនត្រូវមានមេធាវីអមជានិច្ច ។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវបានចាត់តាំងនៅក្នុងលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី» ។
- មាត្រា៣០០(២) ៖ ស្តីពីការចូលខ្លួនរបស់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះបានចែងថា «ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស ។ ជនជាប់ចោទក៏អាចសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួនបានដែរ នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី» ។
- មាត្រា៣០១ ៖ អំពីជំនួយរបស់មេធាវី «ជំនួយមេធាវីត្រូវមានជាចាំបាច់នៅក្នុងករណីដូចតទៅ ៖ ១)ករណីបទឧក្រិដ្ឋ ។ ២)កាលណាជនជាប់ចោទជាអនីតិជន ។ បើគ្មានការជ្រើសរើសដោយជនជាប់ចោទទេ មេធាវីត្រូវបានចាត់តាមគំនិតរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី» ។

ទី៣) ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រង់មាត្រា២៤ថ្មី ។ មាត្រានេះចែងថា «ក្នុងដំណាក់កាលស៊ើបអង្កេត ជនសង្ស័យមានសិទ្ធិទទួលបានការការពារពីមេធាវី ដែលជ្រើសដោយខ្លួនឯង ដោយខានមិនបាន និងមានជំនួយផ្នែកច្បាប់ដល់ពួកគេដោយឥតគិតថ្លៃ ប្រសិនបើខ្លួនគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីពឹងមេធាវី ព្រមទាំងមានសិទ្ធិទទួលបាននូវការបកប្រែចាំបាច់ជាភាសា ដែលជនសង្ស័យនិយាយ និងយល់បាន» ។[៦]

ទី៤) កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រង់មាត្រា១៣ ទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទ ។ មាត្រា១៣(១)ចែងថា«សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិ ឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី ។ សិទ្ធិទាំងនេះរួមមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវនិងជាសាធារណៈ សិទ្ធិត្រូវបានចាត់ទុកថាគ្មានទោសរហូតដល់ពេលរកឃើញថា ជាប់ពិរុទ្ធ សិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង សិទ្ធិមានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួន សិទ្ធិទទួលបាននូវមេធាវីប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលមេធាវីដោយខ្លួនឯង និងសិទ្ធិពិនិត្យ ឬបានពិនិត្យសាក្សីដាក់បន្ទុក» ។ កថាខណ្ឌ២នៃមាត្រាដដែលនេះចែងបន្ថែមថា «អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ឯកភាពគ្នាថា ប្រការស្តីពីសិទ្ធិទទួលបានមេធាវីការពារក្តីនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានន័យថា ជនជាប់ចោទមានសិទ្ធិជ្រើសរើសរកមេធាវីដោយខ្លួនឯងដូចដែលបានធានានៅក្នុងអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ» ។[៧]

ទី៥) វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។[៨] វិធាន៥១(១) នៃវិធានផ្ទៃក្នុងចែងថា «ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងការអង្កេត សហព្រះរាជអាជ្ញាអាចបង្គាប់ឲ្យនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនបុគ្គលណាម្នាក់ ដែលសង្ស័យថា បានចូលរួមនៅក្នុងឧក្រិដ្ឋកម្មណាមួយដែលស្ថិត នៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងឋានៈជាចារី ឬអ្នកសមគំនិត ។ បុគ្គលទាំងនោះ ត្រូវតែបានប្រាប់ពីហេតុផលនៃ

*ការឃាត់ខ្លួន និងសិទ្ធិទាំងឡាយរបស់បុគ្គលនោះដូចមានចែងក្នុងវិធាន២១(១)(ឃ)» ។ វិធាន២១(១)(ឃ) ចែងថា "ជនដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ត្រូវចាត់ទុកថា គ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ ។ ជនទាំងនេះមានសិទ្ធិ ទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់មកចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន...» ។[៩] ក្រៅពីនេះយើងឃើញមានវិធាន ៨១(៣) ចែងថា "នៅពេលជនជាប់ចោទបដិសេធមិនចូលរួមក្នុងនីតិវិធី ជនជាប់ចោទនឹងត្រូវនាំខ្លួនមកកាន់អង្គជំនុំជម្រះសាលាដំបូងដោយកម្លាំងសាធារណៈ ប្រសិនបើចាំបាច់ នៅពេលនោះជនជាប់ចោទត្រូវតែបានជូនដំណឹងអំពីសិទ្ធិដែលត្រូវមានជំនួយមេធាវី តាមការជ្រើសរើសរបស់ខ្លួន ឬសិទ្ធិទទួលបានការចាត់តាំងមេធាវីដូចមានចែងក្នុងវិធានផ្ទៃក្នុងនេះ ឬសិទ្ធិ ការពារក្តីដោយខ្លួនឯង» ។[១០]*

### ១.១) ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌដែលជនគ្រប់រូបមានសិទ្ធិទទួលបានមេធាវីការពារក្តី

***តើជនជាប់ចោទមានសិទ្ធិទទួលបានមេធាវីការពារក្តីតាមការជ្រើសរើសរបស់ខ្លួននៅដំណាក់កាលនីតិវិធីណាខ្លះ?***

យោងតាមមាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធាន ៥១(១) នៃវិធានផ្ទៃក្នុង គឺបានតម្រូវឲ្យផ្តល់ព័ត៌មានដល់ជនសង្ស័យ អំពីសិទ្ធិទទួលបានមេធាវីការពារក្តីចាប់តាំងពីជននោះត្រូវបានឃាត់ខ្លួន ជាលើកដំបូងនៅដំណាក់កាលស៊ើបអង្កេត ដែលអនុវត្តដោយមន្ត្រីនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញាមកម្ល៉េះ ។ ចំណែកមាត្រា១៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា២៨ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ បានធានាដល់ជនត្រូវចោទក្នុងការទទួលបានមេធាវីការពារក្តីតាមការជ្រើសរើសរបស់ខ្លួន ដោយខានមិនបាននៅដំណាក់កាលស៊ើបសួរដែលដឹកនាំ



ផ្ទះ តាម៉ុក នៅអន្លង់វែង ខេត្តឧត្តរមានជ័យ ។ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដោយចៅក្រមស៊ើបអង្កេត ។ បន្ថែមលើនេះ ក្នុងដំណាក់កាលជំនុំជម្រះក្តី មាត្រា៣០១នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធាន ៨១នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ បានធានាដល់ជនដែលត្រូវបានចោទប្រកាន់អំពីបទល្មើសឧក្រិដ្ឋ ដាច់ខាតគឺត្រូវមានមេធាវីការពារក្តី ។ នៅក្នុងន័យនេះ ច្បាប់បានដាក់កាតព្វកិច្ចដល់អង្គជំនុំជម្រះត្រូវធានាថា ដំណើរការជំនុំជម្រះក្តីប្រឆាំងនឹងជនជាប់ចោទ ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋដាច់ខាត គឺត្រូវមានមេធាវីការពារក្តី ។[១១] គួរបញ្ជាក់ថា បទល្មើសដែលមានចែងក្នុងមាត្រា៣ ដល់មាត្រា៨ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺសុទ្ធសឹងតែជាបទល្មើសឧក្រិដ្ឋដែលមានលក្ខណៈធ្ងន់ធ្ងរ[១២] ឬអាចនិយាយម្យ៉ាងទៀតថា អង្គជំនុំជម្រះមានអំណាចវិនិច្ឆ័យទោសតែចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋប៉ុណ្ណោះ ។[១៣]

សរុបសេចក្តីមក យោងតាមមូលដ្ឋានច្បាប់ដូចបានរៀបរាប់ខាងលើ សរបញ្ជាក់ឲ្យឃើញថា នៅគ្រប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទ មានសិទ្ធិទទួលបានមេធាវីការពារក្តីតាមការជ្រើសរើសរបស់ខ្លួន និងទទួលបានដោយឥតគិតថ្លៃ ប្រសិនបើជនទាំងនោះគ្មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីបង់កម្រៃសេវាមេធាវី ។

### ១.២) ការកំណត់អំពីស្ថានភាពក្រីក្ររបស់ជនដែលមានសិទ្ធិទទួលបានមេធាវីការពារក្តី

នៅក្នុងបទបញ្ញត្តិដែលបានរៀបរាប់ខាងលើ បានធានាដល់ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទ ទទួលបានសេវាមេធាវីដោយឥតគិតថ្លៃ ប្រសិនបើជនទាំងនេះពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់កម្រៃសេវាមេធាវី ។ ដូច្នេះសំណួរសំខាន់នោះគឺថា តើមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ដើម្បីកំណត់ថា ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទណាម្នាក់ មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់សេវាមេធាវី?

នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គភាពគាំពារការការពារក្តីមានតួនាទីយ៉ាងសំខាន់ ក្នុងកិច្ចការគាំពារជនជាប់ចោទ ។[១៤] តាមរយៈតួនាទីនេះ ប្រធានអង្គភាពគាំពារការការពារក្តី ត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការសម្រេចថា ជនណាម្នាក់ជាជនក្រីក្រ ព្រមទាំងចាត់តាំងមេធាវីការពារជននោះ ដោយផ្អែកលើបទបញ្ញត្តិស្តីពី«លក្ខណៈវិនិច្ឆ័យក្នុងការកំណត់ជនក្រីក្រ» ។[១៥] គួរបញ្ជាក់ថា លក្ខណៈវិនិច្ឆ័យក្នុងការកំណត់ជនក្រីក្រ គឺមានចែងនៅក្នុងបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី ។ ប៉ុន្តែបទបញ្ជានេះ គឺមិនត្រូវបានផ្សព្វផ្សាយ ឬដាក់បង្ហោះក្នុងគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញឡើយ ។ ចំពោះសេចក្តីសម្រេចរបស់អង្គភាពគាំពារការការពារក្តី ដែលថាជនជាប់ចោទ អៀង សារី, អៀង ធីរិទ្ធ, នួន ជា និង ខៀវ សំផន ជាអសាធនីយជនក៏មិនត្រូវបានបញ្ចេញជាសាធារណៈដែរ ។[១៦] ដូច្នេះយើងមិនអាចបញ្ជាក់ឲ្យបានច្បាស់អំពី«វិធីសាស្រ្តក្នុងការកំណត់ជនក្រីក្រ» នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ យើងនឹងបង្ហាញបទបញ្ញត្តិជាមូលដ្ឋានក្នុងការវិនិច្ឆ័យជនក្រីក្រ ដែលមានចែងក្នុងច្បាប់ស្តីលក្ខន្តិកៈមេធាវីនៃប្រទេសទេសកម្ពុជា ។

មាត្រា៣០នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីបានផ្តល់និយមន័យថា *«ជនក្រីក្រ គឺជាជនដែលគ្មានទ្រព្យ សម្បត្តិ គ្មានប្រាក់ចំណូល ឬដែលមានប្រាក់ចំណូលមិនគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ជីវភាព ។ ការកំណត់ជន ក្រីក្រ គឺត្រូវធ្វើឡើងដោយប្រធានតុលាការ និងក្រឡាបញ្ជីនាយកក្រោយពីបានធ្វើការស៊ើបអង្កេតដល់មូលដ្ឋាន»* ។[១៧] យោងតាមមាត្រានេះ ជនសង្ស័យគឺត្រូវមានកម្រិតជីវភាពទាបបំផុតទើបអាចត្រូវបានវិនិច្ឆ័យថាជាជនក្រីក្រ ។ តើលក្ខខណ្ឌនេះអាចអនុវត្តបានចំពោះជនសង្ស័យណាម្នាក់ដែលត្រូវប្រឈមនឹងការចោទប្រកាន់អំពីបទឧក្រិដ្ឋធ្ងន់ធ្ងរ ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ? ឧទាហរណ៍ ជនសង្ស័យដែលមានដីស្រែចម្ការ ឬប្រាក់ចំណូលសមល្មមសម្រាប់តែផ្គត់ផ្គង់ជីវភាព តើអាចត្រូវបានចាត់ទុកថា គឺជាជនដែលគ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់កម្រៃសេវាមេធាវីដែរឬទេ? ដោយការសន្និដ្ឋាន ជននោះគឺអាចទទួលបានឋានៈជាជនដែលគ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់កម្រៃសេវាមេធាវី ។ ដូច្នេះ លក្ខខណ្ឌដូចមានចែងក្នុងមាត្រា៣០ខាងលើ គឺមិនអាចអនុវត្តបានឡើយ ។ យើងអាចផ្តល់ការពន្យល់ដោយ

សាមញ្ញថា រឿងក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺសុទ្ធសឹងតែជាបទឧក្រិដ្ឋធ្ងន់ធ្ងរ (បទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ...) អំពើឧក្រិដ្ឋបានកើតឡើងស្ទើរគ្រប់ទីកន្លែងនៃផ្ទៃប្រទេសសំណុំរឿងមានភាពស្មុគស្មាញ... ។ ដូច្នេះ គឺតម្រូវឲ្យមេធាវីការពារក្តីត្រូវមានសមត្ថភាពខ្ពស់ ដើម្បីការពារកូនក្តីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ។[១៨] បើជនម្នាក់គ្រាន់តែមានទ្រព្យសម្បត្តិ ឬមានចំណូលត្រឹមតែអាចផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ជននោះគឺទំនងជាមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់កម្រៃសេវាមេធាវីដែលមានសមត្ថភាពសមស្របទៅនឹងលក្ខខណ្ឌតម្រូវនេះឡើយ ។

បច្ចុប្បន្ននេះ បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម គឺត្រូវបានដាក់បញ្ចូលក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ដោយកំណត់ទោសដាក់ពន្ធនាគារអស់មួយជីវិត ។[១៩] ដូច្នេះ លក្ខណៈវិនិច្ឆ័យ និងសេចក្តីសម្រេច ដែលត្រូវបានអនុវត្តដោយអង្គភាពគាំពារការការពារក្តី នឹងក្លាយជាយុត្តិសាស្ត្រដ៏សំខាន់សម្រាប់តុលាការកម្ពុជាក្នុងការកំណត់អំពីភាពក្រីក្រចំពោះជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់នូវបទល្មើសធ្ងន់ធ្ងរទាំងនេះ ។ ពីព្រោះលក្ខខណ្ឌក្នុងការកំណត់ជនក្រីក្រដូចមានចែងក្នុងមាត្រា៣០នៃច្បាប់ស្តីលក្ខន្តិកៈមេធាវី គឺមិនសមស្របចំពោះជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមឡើយ ។

## ២) តើគប្បីអនុវត្ត ឬបោះបង់ចោលនូវសិទ្ធិទទួលបានមេធាវីការពារក្តីដែរ ឬទេ?

ដូចបានបញ្ជាក់រួចមកហើយថា ការសម្រេចអនុវត្ត ឬបោះបង់ចោលនូវសិទ្ធិទទួលបានមេធាវី ការពារក្តី គឺជាសេរីភាពរបស់ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ។ ដូច្នេះជនទាំងនេះត្រូវយល់ដឹងឲ្យបានច្បាស់អំពីនីតិវិធីសំខាន់ៗមួយចំនួន ដែលត្រូវអនុវត្តនៅដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលស៊ើបសួរ ដើម្បីអាចធ្វើជាមូលដ្ឋានក្នុងការសម្រេចអនុវត្ត ឬមិនអនុវត្តសិទ្ធិទទួលបានមេធាវីការពារក្តី ។ នៅក្នុងផ្នែកនេះ យើងនឹងបង្ហាញដោយសង្ខេបអំពីនីតិវិធីសំខាន់ៗ នៅក្នុងដំណាក់កាលទាំងពីរខាងលើ និងបង្ហាញឲ្យឃើញអំពីសារៈសំខាន់ផ្សេងៗ នៅពេលដែលជនសង្ស័យ ឬជនត្រូវចោទសម្រេចទទួលយកមេធាវីការពារក្តី ។ ដោយឡែកនៅដំណាក់កាលជំនុំជម្រះក្តី យើងពុំចាំបាច់ធ្វើការបង្ហាញឡើយ ពីព្រោះច្បាប់បានដាក់កាតព្វកិច្ចដល់អង្គជំនុំជម្រះក្នុងការធានាថា ការជំនុំជម្រះក្តីក្នុងបទឧក្រិដ្ឋ ជនជាប់ចោទ ត្រូវមានមេធាវីការពារក្តី ។[២០]

### ២.១) ដំណាក់កាលស៊ើបអង្កេត

ក្នុងរឿងក្តីព្រហ្មទណ្ឌ សហព្រះរាជអាជ្ញាមានតួនាទីយ៉ាងសំខាន់ក្នុងការចោទប្រកាន់ និងស្វែងរកភស្តុតាងដើម្បីបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។[២១] តាមរយៈតួនាទីនេះ សហព្រះរាជអាជ្ញាត្រូវបានផ្តល់អំណាចជាច្រើនក្នុងការចាត់វិធានការផ្សេងៗដើម្បីប្រមូលភស្តុតាង ។ សហព្រះរាជអាជ្ញាអាចដឹកនាំដោយផ្ទាល់ ឬស្នើឲ្យនគរបាលយុត្តិធម៌ ធ្វើការស៊ើបអង្កេតបឋមដើម្បីកំណត់ភស្តុតាងដែលបង្ហាញអំពីការប្រព្រឹត្តឧក្រិដ្ឋកម្ម ។[២២] ដើម្បីឆ្លើយតបទៅនឹងតម្រូវការស៊ើបអង្កេតនេះ សហព្រះរាជអាជ្ញា អាចបង្គាប់ឲ្យនគរបាលយុត្តិធម៌ធ្វើការកោះហៅ និងសួរយកចម្លើយ[២៣] ព្រមទាំងឃាត់ខ្លួនជនណាម្នាក់ដែលត្រូវបានសង្ស័យថាបានចូលរួមនៅក្នុងឧក្រិដ្ឋកម្មណាមួយ ក្នុងឋានៈជាចារី ឬអ្នកសមគំនិត ។[២៤]

ទោះបីជាយ៉ាងណាក៏ដោយ វិធាន៥១(៥) បានធានាថា នៅពេលដែលជនសង្ស័យណាម្នាក់ មានមេធាវីការពារក្តី ជននោះអាចជួបមេធាវីរបស់ខ្លួនបានរយៈពេល៣០នាទី មុននឹងត្រូវបាននាំទៅបង្ហាញខ្លួននៅចំពោះមុខសហព្រះរាជអាជ្ញា ។ ជាងនេះទៅទៀត មេធាវីមានសិទ្ធិមានវត្តមានក្នុងអំឡុងពេលកូនក្តីរបស់ខ្លួនត្រូវបានឃាត់ខ្លួន ។[២៥] ថ្វីត្បិតវិធាននេះមិនបានចែងច្បាស់ដូចវិធាន ៥៨(២) ដែលថា *"ការសួរចម្លើយជនត្រូវចោទ ត្រូវតែធ្វើឡើងដោយមានវត្តមានរបស់មេធាវី លើកលែងតែជនត្រូវយល់ព្រមឆ្លើយដោយមិនចាំបាច់មានវត្តមានមេធាវីរបស់ខ្លួន..."* ប៉ុន្តែវិធាននេះបានទទួលស្គាល់សិទ្ធិរបស់មេធាវីក្នុងការមានវត្តមាន ក្នុងអំឡុងពេលកូនក្តីរបស់ខ្លួនត្រូវបានឃាត់ខ្លួនសួរយកចម្លើយដោយសហព្រះរាជអាជ្ញា ។ អាចនិយាយបានម្យ៉ាងទៀតថា ក្នុងអំឡុងពេលសួរយកចម្លើយដោយសហព្រះរាជអាជ្ញា ជន

សង្ស័យអាចមានមេធាវីអម លើកលែងតែជននោះសម្រេចបោះបង់សិទ្ធិមានវត្តមានរបស់មេធាវី នៅពេលសួរចម្លើយនោះ ដែលការសម្រេចបោះបង់សិទ្ធិនេះត្រូវតែថតយកសំឡេង ឬរូបភាព ។[២៦] វត្តមានរបស់មេធាវីការពារក្តី នៅក្នុងដំណាក់កាលនេះ គឺពិតជាមានសារៈសំខាន់សម្រាប់ ជនសង្ស័យ ព្រោះដើម្បីធានាថា ការអនុវត្ត"សិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ" ឬ"សិទ្ធិមិនត្រូវបានបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង" គឺត្រូវបានគោរព ។

## ២.២) ដំណាក់កាលស៊ើបសួរ

នេះជាដំណាក់កាលសំខាន់មួយ ដែលជនម្នាក់អាចត្រូវបានសហចៅក្រមស៊ើបអង្កេតសម្រេចលើកលែងការចោទប្រកាន់ និងដោះលែងឲ្យមានសេរីភាព ឬសម្រេចចោទប្រកាន់ និងបញ្ជូនរឿងទៅជំនុំជម្រះតាមរយៈដីកាដំណោះស្រាយ ។ សហចៅក្រមស៊ើបអង្កេតមានតួនាទីយ៉ាងសំខាន់ក្នុងការស៊ើបសួរស្វែងរកភស្តុតាង(ទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក) ដើម្បីធ្វើជាមូលដ្ឋានក្នុងការចេញដីកាដំណោះស្រាយ ។ តាមរយៈតួនាទីនេះ សហចៅក្រមស៊ើបអង្កេតត្រូវបានផ្តល់អំណាចយ៉ាងច្រើនក្នុងការដឹកនាំកិច្ចស៊ើបសួរ ដើម្បីនាំទៅរកការបង្ហាញការពិតនៃរឿងក្តី ។ សហចៅក្រមស៊ើបអង្កេតអាចកោះហៅ និងសួរយកចម្លើយ ជនសង្ស័យ ជនត្រូវចោទ ជនរងគ្រោះ សាក្សី ស្វែងរកមតិយោបល់ពីអ្នកជំនាញ ប្រមូលវត្ថុតាងផ្សេងៗ និងដឹកនាំកិច្ចស៊ើបសួរចុះដល់ទីកន្លែងកើតហេតុ ។[២៧] ក្នុងការអនុវត្តតួនាទីរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតអាចចេញដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន ដីកាបង្គាប់ឲ្យឃុំខ្លួន[២៨] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន[២៩] ដីកាដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៣០] ។ល ។ ដែលដីកាទាំងនេះ គឺសុទ្ធតែប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ជនត្រូវចោទ ។

ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលជនត្រូវចោទមានមេធាវីការពារក្តី នីតិវិធីនៃការសួរយកចម្លើយជនត្រូវចោទ គឺត្រូវបានកំណត់យ៉ាងតឹងរ៉ឹងបំផុត ។ វិធាន៥៨(២) នៃវិធានផ្ទៃក្នុងចែងថា "ការសួរចម្លើយជនត្រូវចោទ ត្រូវតែធ្វើឡើងដោយមានវត្តមានរបស់មេធាវី លើកលែងតែជនត្រូវចោទយល់ព្រមឆ្លើយ ដោយមិនចាំបាច់មានវត្តមានមេធាវីរបស់ខ្លួន និងត្រូវសរសេរចូលក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរមួយដោយឡែក ដោយមានហត្ថលេខា ឬស្នាមម្រាមដៃរបស់ជនត្រូវចោទ ហើយត្រូវដាក់ចូលក្នុងសំណុំរឿង ។ ការយល់ព្រមឆ្លើយដោយមិនចាំបាច់មានវត្តមានមេធាវីរបស់ជនត្រូវចោទ ត្រូវថតទុក..." ។[៣១] កថាខណ្ឌទី៣ បានចែងបន្ថែមថា "ក្នុងករណីបន្ទាន់ ដោយមានការយល់ព្រមពីជនត្រូវចោទ សហចៅក្រមស៊ើបអង្កេតអាចសួរយកចម្លើយជនត្រូវចោទ ដោយមិនចាំបាច់មានវត្តមានរបស់មេធាវី ។ ស្ថានភាពបន្ទាន់ កើតមានឡើងនៅពេលណាដែលមានការជឿជាក់យ៉ាងច្បាស់ថា អាចបាត់បង់ជារៀងរហូតនូវភស្តុតាង នៅខណៈពេលរង់ចាំមេធាវីមកដល់ ដូចជាជនត្រូវចោទជិតដល់ពេលស្លាប់ជាដើម" ។ យោងតាមវិធាន ៥៨(២,៣) នេះ នៅពេលជនត្រូវចោទបានសម្រេចអនុវត្តសិទ្ធិទទួលបានមេធាវីការពារក្តី នោះសហចៅក្រមស៊ើបអង្កេតមិនអាចសួរយកចម្លើយពីជនត្រូវចោទដោយគ្មានវត្តមានរបស់មេធាវីបានឡើយ លើកលែងតែជនត្រូវចោទនោះ "យល់ព្រមឆ្លើយដោយមិនចាំបាច់មានវត្តមានរបស់មេធាវី" ឬ"មានករណីបន្ទាន់"តែប៉ុណ្ណោះ ។ ដូចបានបញ្ជាក់ម្តងរួចហើយថា វត្តមានរបស់មេធាវីក្នុងអំឡុងពេលកូនក្តីរបស់ខ្លួនត្រូវបានសួរយកចម្លើយដោយសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេត គឺមានសារៈសំខាន់ដើម្បីធានាថា ការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបសំណួរ សិទ្ធិមិនត្រូវបានបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង ឬសិទ្ធិផ្សេងៗទៀតរបស់ជនត្រូវចោទ គឺមិនត្រូវរំលោភបំពាន ។

នៅក្នុងដំណាក់កាលស៊ើបសួរនេះ មេធាវីមានតួនាទីយ៉ាងសំខាន់ក្នុងការការពារកូនក្តីរបស់ខ្លួន ។ ក្រៅពីសិទ្ធិមានវត្តមានក្នុងអំឡុងពេលសហចៅក្រមស៊ើបអង្កេតសួរយកចម្លើយកូនក្តីរបស់ខ្លួន មេធាវីការពារក្តីមានសិទ្ធិផ្តល់ការពិគ្រោះយោបល់ដល់ជនត្រូវចោទ មុនពេលជននោះត្រូវបាននាំទៅសួរចម្លើយ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ។[៣២] សំខាន់ជាងនេះទៀត មេធាវីមានសិទ្ធិពិនិត្យមើលសំណុំរឿងច្បាប់ដើម និងថតចម្លងសំណុំរឿងបានគ្រប់ពេលវេលា ។[៣៣] វិធាន៥៥(៦) ចែងថា "...សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីទាំងអស់ មានសិទ្ធិគ្រប់ពេលវេលាក្នុងការពិនិត្យ និងថតចម្លងសំណុំរឿង ក្រោមការឃ្លាំមើលរបស់

ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងម៉ោងធ្វើការ និងគោរព ទៅតាមបទបញ្ជារបស់អង្គជំនុំជម្រះវិសាមញ្ញ» ។ យោងតាមវិធាននេះ គឺមានតែ«សហព្រះរាជអាជ្ញា» និង«មេធាវីរបស់ភាគី»ប៉ុណ្ណោះ ដែលមានសិទ្ធិពិនិត្យមើល និងថតចម្លងសំណុំរឿង ។ ចំណែកជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលជាភាគី គឺមិនត្រូវបានរាប់បញ្ចូលនៅក្នុងសិទ្ធិនេះឡើយ ។ គួរបញ្ជាក់ថាពាក្យ «ភាគី» គឺសំដៅទៅលើសហព្រះរាជអាជ្ញា ជនត្រូវចោទ ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។[៣៤] ការទទួលបានព័ត៌មានគ្រប់គ្រាន់ (ភស្តុតាងផ្សេងៗ) ពីសំណុំរឿង គឺមានសារៈសំខាន់បំផុត សម្រាប់ជនត្រូវចោទ ដើម្បីត្រៀមការពារខ្លួនទុកជាមុន ។

តួនាទីដ៏សំខាន់មួយទៀតរបស់មេធាវីការពារក្តី គឺការចូលរួមក្នុងសវនាការតទល់គ្នានៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដែលសវនាការនេះអាចឈានទៅដល់ការសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ឬដោះលែងឲ្យមានសេរីភាព ។ វិធាន ៦៣(១)(ក) ចែងថា «សហចៅក្រមស៊ើបអង្កេត អាចសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នក្រោយពេលមានសវនាការតទល់គ្នា ។ ......ក្នុងសវនាការតទល់គ្នានេះ សហចៅក្រមស៊ើបអង្កេតត្រូវស្តាប់សហព្រះរាជអាជ្ញា ជនត្រូវចោទ និងមេធាវីជនត្រូវចោទ ។ នៅពេលបញ្ចប់សវនាការតទល់គ្នា សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ ត្រូវបានដោះលែងឲ្យមានសេរីភាព...» ។[៣៥] ជាងនេះទៅទៀត ក្នុងករណីជនត្រូវចោទត្រូវបានសម្រេច ឃុំខ្លួនបណ្តោះអាសន្ន ក្នុងអំឡុងពេលនៃការឃុំខ្លួននោះ មេធាវីអាចធ្វើសំណើទៅសហចៅក្រមស៊ើបអង្កេតសុំឲ្យដោះលែងកូនក្តីរបស់ខ្លួនបានគ្រប់ពេលវេលា ។[៣៦]

### ៣) ការអនុវត្តជាក់ស្តែងក្នុងសំណុំរឿង០០៣ និង ០០៤

បច្ចុប្បន្នសំណុំរឿង០០៣ និង០០៤ គឺកំពុងស្ថិតនៅក្រោមការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត ។ ឈ្មោះជនសង្ស័យនៅក្នុងសំណុំរឿងទាំងពីរនេះ គឺត្រូវបានការិយាល័យសហព្រះរាជអាជ្ញាបញ្ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ដើម្បីធ្វើការស៊ើបសួរ និងចោទប្រកាន់បន្ថែម ។ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងស្តីពីការបិទបញ្ចប់ការស៊ើបសួរលើសំណុំរឿងទាំងពីរនេះ ។ ចាប់ពីទទួលបានសំណុំរឿងនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ រហូតដល់ថ្ងៃចេញសេចក្តីជូនដំណឹងស្តីពីការបិទបញ្ចប់ការស៊ើបសួរនេះ សហចៅក្រមស៊ើបអង្កេតបានបើកកិច្ចស៊ើបសួរលើសំណុំរឿងទាំងនេះ ដោយគ្មានវត្តមានរបស់មេធាវីការពារក្តី ។[៣៧] ក្នុងករណីនេះ ទោះបីជនត្រូវចោទនៅក្នុង



យោធា និងកងការពារខ្មែរក្រហម ថតជាមួយទីប្រឹក្សា និ
(បណ្ណសារ ៖ មជ្ឈម

សំណុំរឿងទាំងពីរនេះមិនទាន់ត្រូវបាននាំមកឃុំខ្លួននៅមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប៉ុន្តែសិទ្ធិមួយចំនួនរបស់ជនត្រូវចោទដូចបានរៀបរាប់នៅក្នុងចំណុចទី២ខាងលើ គឺត្រូវបានបាត់បង់ ។ ការខាតបង់នេះ ជាក់ស្តែងណាស់គឺបណ្តាលមកពីជនត្រូវចោទទាំងនោះមិនមានមេធាវីការពារក្តី ។ ថ្វីត្បិតការិយាល័យសហចៅក្រម ស៊ើបអង្កេតត្រូវបានទទួលស្គាល់ថាជាស្ថាប័នមួយដែលមានតួនាទីយ៉ាងសំខាន់ក្នុងការស៊ើបអង្កេត ដោយស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុក ព្រមទាំង

ដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ដើម្បីនាំទៅរកការបង្ហាញការពិតនៃរឿងក្តីក៏ដោយ[៣៨] ប៉ុន្តែសម្រាប់ការអនុវត្ត គឺនៅតែមានភាពខ្វះចន្លោះ ។[៣៩] ដូច្នេះ នៅក្នុងដំណាក់កាលស៊ើបសួរ មេធាវីមានតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកធ្វើឲ្យកិច្ចស៊ើបសួរកាន់តែមានភាពសុក្រឹត និងមានប្រសិទ្ធភាព ។



...ងអ្នកជំនាញចិន នៅអង្គរវត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។
...ណ្ឌលឯកសារកម្ពុជា)

១ គួរបញ្ជាក់ថា ពាក្យ ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទ ដែលប្រើនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺត្រូវបានប្រើក្នុងបរិបទផ្សេងៗគ្នា ។ តាមសន្ទានុក្រមនៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះ ពាក្យ"ជនសង្ស័យ" គឺសំដៅទៅលើបុគ្គលដែលសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេតចាត់ទុកថា អាចធ្លាប់បានប្រព្រឹត្តបទឧក្រិដ្ឋដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ប៉ុន្តែមិនទាន់ត្រូវបានចោទប្រកាន់នៅឡើយ ។ ពាក្យ"ជនត្រូវចោទ" គឺសំដៅទៅលើបុគ្គលណាម្នាក់ ដែលត្រូវចោទប្រកាន់ចំពោះរឿងក្តីណាមួយ ក្នុងចន្លោះពេលពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររហូតដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់ ។ ចំណែកពាក្យ"ជនជាប់ចោទ" គឺសំដៅទៅលើបុគ្គលដែលត្រូវបានចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ។

២ សូមមើលមាត្រា ៦៧(១) នៃលក្ខន្តិកៈរបស់ (ICC), មាត្រា ២១(៤) នៃលក្ខន្តិកៈរបស់ (ICTY), មាត្រា ២០(៤) នៃលក្ខន្តិកៈរបស់ (ICTR) និងមាត្រា១៧(៤) នៃលក្ខន្តិកៈរបស់ (SCSL) ។

៣ សូមមើល"សេចក្តីសម្រេចលើសំណើរបស់អង្គភាពគាំពារការការពារក្តីសុំផ្អាកដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសុំឲ្យមានវិធានការទាក់ទងនឹងការតំណាងប្រកបដោយប្រសិទ្ធិភាពជូនជនសង្ស័យក្នុងសំណុំរឿង០០៣" ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ ឯកសារលេខ (Nº 3) ត្រង់កថាខណ្ឌទី១១ ។ អាចរកមើលផងដែរក្នុង"សេចក្តីសម្រេច លើសំណើរបស់អង្គភាពគាំពារការការពារក្តីសុំផ្អាកដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសុំឲ្យមានវិធានការទាក់ទងនឹងការតំណាងប្រកបដោយប្រសិទ្ធិភាពជូនជនសង្ស័យក្នុងសំណុំរឿង០០៤" ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ត្រង់កថាខណ្ឌទី១១ ។ គួរបញ្ជាក់ថា សេចក្តីសម្រេចទាំងពីរនេះ គឺមានលក្ខណៈដូចគ្នាស្ទើរទាំងស្រុង លើកលែងតែលេខសំណុំរឿង និងកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេចតែប៉ុណ្ណោះ ។ ឯកសារទាំងពីរអាចរកបានក្នុងគេហទំព័រ :
http://www.eccc.gov.kh/document/court/16339
និង http://www.eccc.gov.kh/document/court/16844

៤ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ។

៥ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

៦ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៦ (ហៅកាត់ថាច្បាប់ស្តីពីការបង្កើត អ.វ.ត.ក) ។

អាចរកបានក្នុងគេហទំព័រ : http://www.eccc.gov.kh/document/legal/law-on-eccc

៧ កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ។ អាចរកបានក្នុងគេហទំព័រ : http://www.eccc.gov.kh/document/legal/agreement

៨ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មលើកទី៨ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ ហៅកាត់ថា "វិធានផ្ទៃក្នុង" ។ អាចរកបានក្នុងគេហទំព័រ http://www.eccc.gov.kh/document/legal/15232

៩ វិធាន ២១(១)(ឃ) នៃវិធានផ្ទៃក្នុង ។

១០ វិធាន ៨១(៣) នៃវិធានផ្ទៃក្នុង ។

១១ មាត្រា៣០១ និងវិធាន៨១(៣,៤)

១២ មាត្រា៣ ចែងពីអំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការវាយប្រហារលើសាសនា, មាត្រា៤ ចែងពីអំពើប្រល័យពូជសាសន៍, មាត្រា៥ ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, មាត្រា៦ ស្តីពីការបំពាន់យ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ, មាត្រា៧ ស្តីពីការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្នុងពេលមានជម្លោះប្រដាប់អាវុធ និងមាត្រា៨ ចែងអំពីអំពើឧក្រិដ្ឋកម្មប្រឆាំងលើអ្នកដែលទទួលបានការការពារជាអន្តរជាតិ យោងតាមអនុញ្ញាទីក្រុងវីយ៉ែនស្តីពីទំនាក់ទំនងការទូត ។

១៣ សូមមើលមាត្រា១ និងមាត្រា២ នៃកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

១៤ អង្គភាពគាំពារការការពារក្តីមានតួនាទីយ៉ាងសំខាន់ក្នុងការគាំពារជនជាប់ចោទ ដើម្បីធានាថា ការជំនុំជម្រះក្តីបានប្រព្រឹត្តទៅប្រកបដោយយុត្តិធម៌ ។ សូមមើលលម្អិតក្នុងគេហទំព័រ : http://www.eccc.gov.kh/dss/defence-support-section-dss

១៥ វិធាន១១(៦) ចែងថា "ប្រធានអង្គអង្គភាពគាំពារការការពារក្តីត្រូវសម្រេចអំពីជនណាម្នាក់ជាជនក្រីក្រ និងការចាត់តាំងមេធាវីការពារជនក្រីក្រ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលកំណត់នៅក្នុងបទបញ្ជារដ្ឋបាលនៃអង្គភាពគាំពារការការពារក្តី ។ សេចក្តីសម្រេចបើកផ្លូវប្តឹងតវ៉ាទៅសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ..." ។ គួរបញ្ជាក់ថា បទបញ្ញត្តិស្តីពីលក្ខណៈវិនិច្ឆ័យក្នុងកំណត់ជនក្រីក្រ គឺត្រូវបានអនុម័តដោយអង្គភាពគាំពារការការពារក្តី [វិធាន១១(២)(ក.៣)] ។

១៦ "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះដីកាសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងទ្រព្យសម្បត្តិទាំងអស់ដែលជនត្រូវចោទមាន" របស់អង្គបុរេជំនុំជម្រះ (ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០ ឯកសារលេខ D193/5/5 ត្រង់កថាខណ្ឌទី៤ អាចរកបានក្នុងគេហទំព័រ : http://www.eccc.gov.kh/search/node/D193/5/5) បានដកស្រង់សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតថា "...ផ្នែកគាំពារការការក្តីបានរកឃើញពីពេលមុនថា ជនត្រូវចោទជាអសាធនីយជន..." ។ សេចក្តីសម្រេចនេះចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០១០ ឯកសារ D193/4 (ឯកសារនេះមិនត្រូវបានបញ្ចេញជាសាធារណៈឡើយ) ។ គួរបញ្ជាក់ថា ឯកសារនានាដែលពាក់ព័ន្ធនឹងសំណើសុំស៊ើបអង្កេតទ្រព្យសម្បត្តិរបស់ជនជាប់ចោទក្នុងសំណុំរឿង ០០២ គឺត្រូវបានចាត់ថ្នាក់ថាជាឯកសារសម្ងាត់ (សូមមើលឯកសារ D193/5/5 ត្រង់កថាខណ្ឌទី១) ។

១៧ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ប្រកាសឲ្យប្រើដោយព្រះរាជក្រម នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ។

១៨ គោលការណ៍ស្តីពីតួនាទីរបស់មេធាវី ដែលត្រូវបានអនុម័តដោយសមាជអង្គការសហប្រជាជាតិ ត្រង់កថាខណ្ឌទី៦ ចែងថា "ជនណាក៏ដោយដែលមិនមានមេធាវី មានសិទ្ធិទទួលមេធាវីម្នាក់ដែលមានបទពិសោធន៍ និងសមត្ថភាពប្រហាក់ប្រហែលទៅនឹងចរិកនៃបទល្មើសដែលចោទប្រកាន់មកលើខ្លួន ក្នុងគ្រប់រឿងក្តីទាំងអស់ដែលផលប្រយោជន៍យុត្តិធម៌តម្រូវ ដូច្នេះដើម្បីឲ្យមេធាវីនោះផ្តល់នូវជំនួយផ្នែកច្បាប់ប្រកបដោយប្រសិទ្ធភាព..." ។ អាចរកបានក្នុងគេហទំព័រ : http://www2.ohchr.org/english/law/lawyers.htm

១៩ ក្រមព្រហ្មទណ្ឌកម្ពុជា ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ។ មាត្រា១៨៣ ចែងពី"បទឧក្រិដ្ឋប្រល័យពូជសាសន៍", មាត្រា១៨៨ ចែងពី"បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ" និងមាត្រា១៩៣ ចែងពី"បទឧក្រិដ្ឋសង្គ្រាម" ។

២០ សូមមើលក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាត្រង់មាត្រា៣០១ និងវិធាន៨១(៤) នៃវិធានផ្ទៃក្នុង ។

២១ វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង

២២ វិធាន ៩០(១) នៃវិធានផ្ទៃក្នុង

២៣ វិធាន ៥០(៤)នៃវិធានផ្ទៃក្នុង

២៤ វិធាន ៥១(១)នៃវិធានផ្ទៃក្នុង

២៥ វិធាន ៥១(៥)នៃវិធានផ្ទៃក្នុង

២៦ វិធាន ២៥(១) ចែងថា "ក្នុងគ្រប់កាលៈទេសៈដែលអាចធ្វើទៅបាននៅពេលសហព្រះរាជអាជ្ញា ឬសហចៅក្រមស៊ើបអង្កេតសួរយកចម្លើយពីជនសង្ស័យ ឬជនត្រូវចោទ ត្រូវតែថតយកសំឡេង ឬរូបភាព" ។ ចំណុច(ខ)នៃវិធាននេះ បានបន្ថែមថា "ការបោះបង់សិទ្ធិមានវត្តមានមេធាវីក្នុងពេលសួរចម្លើយត្រូវថតយកសំឡេង ឬរូបភាព" ។

២៧ វិធាន ៥៥(៥)(ក)នៃវិធានផ្ទៃក្នុង

២៨ វិធាន ៥៥(៥)(ឃ)នៃវិធានផ្ទៃក្នុង

២៩ វិធាន ៦៣ នៃវិធានផ្ទៃក្នុង

៣០ វិធាន ៦៥ នៃវិធានផ្ទៃក្នុង

៣១ វិធាន ៥៨(២) នៃវិធានផ្ទៃក្នុង

៣២ វិធាន ៥៧(១) នៃវិធានផ្ទៃក្នុង

៣៣ វិធាន ៥៥(៦,១១) នៃវិធានផ្ទៃក្នុង

៣៤ សូមមើលសន្ទានុក្រមនៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រង់ទំព័រ១៣៦ ។

៣៥ វិធាន ៦៣(១)(ក) នៃវិធានផ្ទៃក្នុង

៣៦ វិធាន ៦៤(២) នៃវិធានផ្ទៃក្នុង

៣៧ សូមមើល"សំណើរបស់អង្គភាពគាំពារការការពារក្តី សុំផ្អាក ដំណើរការនីតិវិធីនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងសុំឲ្យមានវិធានការទាក់ទងនឹងការតំណាងប្រកបដោយប្រសិទ្ធភាព ជូនជនសង្ស័យក្នុងសំណុំរឿង០០៣" ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១ ឯកសារលេខ (១) ត្រង់កថាខណ្ឌ ទី៧ ។ អាចរកបានក្នុងគេហទំព័រ www.eccc.gov.kh/document/court/16445

៣៨ វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង

៣៩ សវនាការស្តាប់សក្ខីកម្មរបស់សាក្សីក្នុងសំណុំរឿង០០២ បានបង្ហាញថា ការសួរយកចម្លើយរបស់សាក្សីដោយអ្នកស៊ើបអង្កេត គឺនៅមានភាពខ្វះចន្លោះមួយចំនួន ។ ជាក់ស្តែងសវនា ការស្តាប់សក្ខីកម្មរបស់សាក្សី នង សុផង់ សក្ខីកម្មមួយចំនួន ដែលសាក្សីបានផ្តល់ជូនសហចៅក្រមស៊ើបអង្កេត ត្រូវបានសាក្សីប្រកាសលុបចោលនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។ សាក្សីបានលើកសំណើថា "...សំណូមពរឲ្យអង្គសវនាការ លុបចោលនូវពាក្យទាំងឡាយណាដែលខ្ញុំបានផ្តល់បទសម្ភាសន៍ជូនចៅក្រមស៊ើបអង្កេត គ្រប់ពាក្យទាំងអស់នៅក្នុងបទសម្ភាសន៍ ហ្នឹងដែលមានពាក្យ ប្រហែល អាច ឬតាមខ្ញុំស្មាន ចេញទៅកុំទុក ជាការ ពីព្រោះគឺខ្ញុំមិនបានដឹង" ។ សូមមើលប្រតិចារិកថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ ត្រង់ទំព័រ៥៨ និង៥៩ ។ អាចរកបានក្នុងគេហទំព័រ http://www.eccc.gov.kh/document/court/22495 ។



សិស្សានុសិស្សនៃវិទ្យាល័យក្រចេះក្រុងចូលរួមស្តាប់ការធ្វើបទបង្ហាញរបស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា អំពីការវិវត្តសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ (បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)



កូនស្រីរបស់កម្មាភិបាលខ្មែរក្រហមក្នុងរបបកម្ពុជាប្រធិបតេយ្យ ។ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)



កងសិល្បៈនារីខ្មែរក្រហមស្លៀកសម្លៀកបំពាក់ប្រពៃណីខ្មែរទទួលគណៈប្រតិភូបរទេសដែលមកធ្វើទស្សនកិច្ចនៅកម្ពុជា
ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ពន្យល់ពាក្យសំខាន់ៗ

**១**–ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ៖ សំដៅទៅលើដីកាជាលាយលក្ខណ៍អក្សរ ដែលចេញដោយសហព្រះរាជអាជ្ញា ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបើកការស៊ើបសួរ ចំពោះករណីបទល្មើសណាមួយ និងធ្វើការចោទប្រកាន់ ។

**២**–ដីកាសន្និដ្ឋានស្ដាពរ ៖ សំដៅទៅលើដីកាជាលាយលក្ខណ៍អក្សរ ដែលចេញដោយសហព្រះរាជអាជ្ញាស្នើសុំទៅសហចៅក្រមស៊ើបអង្កេតឲ្យធ្វើដីកាដំណោះស្រាយចំពោះសំណុំរឿងណាមួយ ។

**៣**–ដីកាដំណោះស្រាយ ៖ សំដៅទៅលើដីកាចុងក្រោយ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ នៅពេលបញ្ចប់ការស៊ើបសួរដែលអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ ។


# មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល ៖ dccam@online.com.kh

គេហទំព័រ ៖ www.dccam.org ឬ www.cambodiatribunal.org



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពី

*Bereau of Democracy, Human Rights, and Labor,*

*U.S. Department of State*


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | នួន ជា (ឡុង រិទ្ធ) | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឌី សុជាតា**

បរិញ្ញាបត្រច្បាប់ សិក្សាជាភាសាអង់គ្លេស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លឹម ជ័យច័ត្ត**

បរិញ្ញាបត្រច្បាប់ និងបរិញ្ញាបត្រសេដ្ឋកិច្ចពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាជ័យលាភីថ្នាក់ជាតិ ទទួលបានពានរង្វាន់មេដាយមាសក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។



**ទូន ខ្សៃហុល**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ចាន់ ប្រាថ្នា**

បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



កុមារា-កុមារីដែលឪពុកម្ដាយរបស់ខ្លួនត្រូវបានខ្មែរក្រហមសម្លាប់ ។ ក្នុងឆ្នាំ១៩៧៩ កុមារា-កុមារីទាំងនេះ បានធ្វើដំណើរគ្រាច់ចរគ្មានគោលដៅដើម្បីស្វែងរកម្ហូបអាហារ និងសាច់ញាតិ ។ រូបនេះថតដោយទាហានវៀតណាមក្នុងខែមករា ឆ្នាំ១៩៧៩ នៅខេត្តសៀមរាប ។
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)